**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# កិច្ចសន្យាសេវាកម្ម

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤


រៀបរៀងឡើងដោយ

និស្សិតឈ្មោះ **ស៊ាខ ណារ៉ា**

**ឆឿន ណូវែល**

សាស្ត្រាចារ្យណែនាំ

លោក **ជិន វណ្ណារ៉ា**



ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០

ឆ្នាំសរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ធឿន ណូវែល** និងខ្ញុំបាទឈ្មោះ **ស៊ាង ណារ៉ា** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០១៣-២០១៤។ ជាបឋម យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និងសម្តែងនូវការដឹងគុណកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតចំពោះ

-អ្នកម្តាយ **ឃុន សុភានី** និងវិញ្ញាណខន្ធលោកឪពុក **ប៉ៅ ធឿន**

-លោកឪពុក **ស៊ាង ណារិទ្ធ** និង អ្នកម្តាយ **ឡៅ សំបូន**

ដែលលោកទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាកូន ទំនុកបម្រុងកូន ហើយបំពេញតម្រូវការរបស់កូនដោយមិនឱ្យកូនខ្វះខាតអ្វីឡើយ។ លើសពីនេះទៅទៀត លោកទាំងពីរបានផ្តត់ផ្គង់នូវប្រាក់កាស ឱ្យកូនបានសិក្សារៀនសូត្រតាំងពីមត្តេយ្យ រហូតដល់ថ្នាក់ឧត្តមសិក្សា ដើម្បីឱ្យកូនបានក្រេបយកចំនេះវិជ្ជា ដើម្បីជាប្រយោជន៍យកទៅ ប្រើប្រាស់នាថ្ងៃអនាគត។ ក្រៅពីនេះ លោកទាំងពីរបានអប់រំទូន្មានកូនឱ្យខិតខំរៀនសូត្រ ដើម្បីក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គម ហើយជៀសវាងនូវអំពើអបាយមុខទាំងឡាយ។ យើងខ្ញុំមិនអាចភ្លេចបាននូវ គុណូបក្ការៈដ៏ថ្លៃថ្លា ធំធេង មិនអាចកាត់ថ្លៃបានឡើយ មានតែប្រាមដៃដប់ បន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិ ជួយតាមថែរក្សាលោកទាំងពីរ ហើយយើងខ្ញុំនឹងតបស្នងសងគុណលោកទាំងពីរ ដោយភាពដឹងគុណជានិច្ចរៀងរហូត។

យើងខ្ញុំក៏សូមថ្លែងអំណរគុណ ចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រមទាំងសាស្ត្រាចារ្យខ្មែរ និង បរទេសទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំ បង្ហាត់បង្រៀន ផ្តល់នូវចំនេះដឹងដល់យើងខ្ញុំ តាំងពីឆ្នាំទីមួយរហូតដល់ឆ្នាំទីបួន។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅបំផុត ចំពោះលោកគ្រូសាស្ត្រាចារ្យ **ខិន វណ្ណារ៉ា** ដែលជាសាស្ត្រាចារ្យទទួលបន្ទុកណែនាំសារណា លោកបានលះបង់ពេលវេលាដ៏មាន តំលៃ និងខិតខំអស់ពីកំលាំងកាយចិត្ត និងយកចិត្តទុកដាក់ក្នុងការពន្យល់នែនាំចង្អុលបង្ហាញឱ្យយើងខ្ញុំ ចេះធ្វើប្លង់ តាក់តែងឃ្លាឃ្លោងនិងកែសម្រួល រាល់កំហុសឆ្គងទាំងឡាយ ក្នុងការសរសេរចងក្រង ជាសារណា នេះឡើងដោយលោកមិនធុញទ្រាំនឿយណាយបន្តិចសោះឡើយ។

ជាចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងសាស្ត្រាចារ្យ ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អោយមានសុខភាពល្អ និងទទួលបានជោគជ័យក្នុងការបំពេញគ្រប់ ភារកិច្ចទាំងអស់។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រអស់រយៈពេល៤ឆ្នាំ ចាប់ពីឆ្នាំ២០១០-២០១៤ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៤ ក្រុម $L_4A_3$ យើងខ្ញុំជានិស្សិតបានទទួលនូវចំណេះដឹងជាច្រើនទាំងចំនេះដឹងខាងមុខជំនាញ និងចំនេះដឹងផ្នែកសង្គមការងារផងដែរ ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀនយើងខ្ញុំអស់ពី កំលាំងកាយចិត្ត រហូតដល់យើងខ្ញុំទទួលបានលទ្ធផលល្អដល់សព្វថ្ងៃនេះ។ ដូច្នេះហើយ ដើម្បីវាយតំលៃលើចំនេះដឹងរបស់យើងខ្ញុំ យើងខ្ញុំសូមលើកយកប្រធានបទស្តីពី **កិច្ចសន្យាសេវាកម្ម** មកធ្វើការស្រាវជ្រាវ សរសេរជាសារណា ក្នុងការបញ្ចប់នូវការសិក្សាថ្នាក់បរិញ្ញាបត្ររបស់យើងខ្ញុំទាំងពីរនាក់។

មូលហេតុដែលយើងខ្ញុំទាំងពីរនាក់លើកយកប្រធានបទនេះ មកសរសេរបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រដោយសារ តែយើងខ្ញុំយល់ថា កិច្ចសន្យាសេវាកម្ម ជាកិច្ចសន្យាមួយស្ថិតក្នុងប្រពន្ធ័សេដ្ឋកិច្ច ទីផ្សារសេរី ហើយស្របទៅនឹងភាពរីកចំរើននៃប្រព័ន្ធសកលភាវូបនីយកម្ម។

ម៉្យាងវិញទៀតយើងខ្ញុំយល់ឃើញថា ឯកសារដែលយើងទាំងពីរ សរសេរនេះនឹងក្លាយជាបច្ច័យ មួយសម្រាប់កិច្ចការស្រាវជ្រាវ ដែលលោកសាស្ត្រាចារ្យបានដាក់ឱ្យ ឫយកទៅធ្វើជាឯកសារដើម្បីអាន ពង្រីកនូវចំនេះដឹងបន្ថែមទៀត។ ទន្ទឹមនឹងនេះដែររាល់ការលើកបង្ហាញ និងការបញ្ចេញទស្សនៈនៅក្នុង ឯកសារនេះ មុខជានិងមានភាពខ្វះចន្លោះនៅត្រង់កន្លែងខ្លះជាក់ជាពុំខាន ដូច្នេះហើយយើងខ្ញុំទាំងពីរនាក់រីករាយ នឹងទទួលនូវរាល់ការរិះគន់ទាំងឡាយ ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដើម្បីជាបទពិសោធន៍ និងជួយឱ្យយើងខ្ញុំអភិវឌ្ឍនូវរាល់កំហុសខ្វះខាតទាំងនោះ ឱ្យបានល្អប្រសើរ។

ជាការថ្លែងនូវសេចក្តីអំណរគុណ យើងខ្ញុំសូមបួងសួងប្រសិទ្ធពរជ័យ បវរសួស្តី សេរីមង្គលជូនដល់អស់លោក លោកស្រី និងមិត្តអ្នកអានទាំងអស់សូមទទួលបានជោគជ័យគ្រប់ភារកិច្ចការងារ និងការសិក្សាដែលអស់លោក លោកស្រី និងមិត្តអ្នកអានបានចំណាយពេលវេលាដ៏មានតំលៃអានសារណារបស់យើងខ្ញុំទាំងពីរនាក់។

# មាតិកា


ទំព័រ

**សេចក្ដីផ្ដើម** ........ ១

**ជំពូក ១ កិច្ចសន្យាម៉ៅការ**

**១.១. និយមន័យ និងគោលគំនិត** ........ ៣

**១.២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ** ........ ៣

**១.៣. ពេលដែលត្រូវបង់កម្រៃ** ........ ៤

**១.៤. កាតព្វកិច្ចរបស់ម្ចាស់ការ** ........ ៥

១.៤.១. កាតព្វកិច្ចបង់កម្រៃ ........ ៥

១.៤.២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ........ ៥

**១.៥. កាតព្វកិច្ចរបស់អ្នកម៉ៅការ** ........ ៥

១.៥.១. ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ ........ ៥

១.៥.១.១. គោលគំនិត ........ ៦

១.៥.១.២. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ក្នុងករណីដែលការងារមានវិការៈ.. ៧

១.៥.២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ........ ១៣

**១.៦. ការបញ្ចប់កិច្ចសន្យាម៉ៅការ** ........ ១៤

១.៦.១. សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសម្រេច ........ ១៤

១.៦.២. ការរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ........ ១៤

**១.៧. កិច្ចសន្យាម៉ៅការពាណិជ្ជកម្ម** ........ ១៥

១.៧.១. កាតព្វកិច្ចរបស់អ្នកម៉ៅការ និង កាតព្វកិច្ចរបស់ម្ចាស់ការ ........ ១៥

១.៧.២. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ........ ១៧

១.៧.៣. ការបញ្ចប់កិច្ចសន្យាម៉ៅការពាណិជ្ជកម្ម ........ ១៨

**ជំពូក ២ បញ្ញើ**

**២.១. បទបញ្ញត្តិស្ដីពីបញ្ញើ** ........ ១៩

២.១.១. និយមន័យ ........ ១៩

២.១.២. លក្ខណៈរបស់កិច្ចសន្យាបញ្ញើ ........ ២០

២.១.២.១. កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ ........ ២០

២.១.២.២. គោលការណ៍មិនយកកម្រៃ ........ ២០

២.១.២.៣. អនុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀង ..............................២១
២.១.២.៤. កិច្ចសន្យាបញ្ញើដែលបានធ្វើដោយអ្នកគ្មានកម្មសិទ្ធិ ..........................២១
២.១.៣. ករណីយកិច្ច និងកាទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ................................ ២២
២.១.៣.១. ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ.............................................. ២២
២.១.៣.២. ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ ................................២៣
២.១.៣.៣. ករណីយកិច្ចសងរបស់ អ្នកទទួលបញ្ញើ ........................................២៣
២.១.៣.៤. ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ..........................................២៤
២.១.៤. ករណីយកិច្ចរបស់អ្នកផ្ញើ..........................................................................២៦
**២.២. បញ្ញើដោយរួមបញ្ចូលគ្នា និងបញ្ញើបរិភោគ**..............................................................២៦
២.២.១. បញ្ញើដោយរួមបញ្ចូលគ្នា.........................................................................២៧
២.២.២. បញ្ញើបរិភោគ .......................................................................................២៧
**២.៣. វិសុណ្ណាប័ន** ............................................................................................................២៧
២.៣.១. និយមន័យ ............................................................................................២៨
២.៣.២. លក្ខខណ្ឌនៃសុពលភាព ............................................................................២៨
២.៣.៣. ភាគីនៃវិសុណ្ណាប័ន ..................................................................................២៨
២.៣.៤. ការរំលាយកិច្ចសន្យាវិសុណ្ណាប័ន .................................................................២៩

## ជំពូក ៣ អាណាត្តិ

**៣.១. និយមន័យ និង និដ្ឋភាពទូទៅ**............................................................................ ៣០
**៣.២. លក្ខខណ្ឌ**.................................................................................................................. ៣១
**៣.៣. ទំនាក់ទំនងរវាង អាណាត្តិ និង ការតំណាង** ........................................................ ៣១
**៣.៤. ភាតព្វកិច្ចរបស់អាណាត្តិគាហក**............................................................................៣២
៣.៤.១. ករណីយកិច្ចប្រុងប្រយ័ត្ន ..........................................................................៣២
៣.៤.២. ករណីយកិច្ចរាយការណ៍ ........................................................................... ៣៣
៣.៤.៣. កាតព្វកិច្ចប្រគល់ .................................................................................... ៣៤
៣.៤.៤. ការទទួលខុសត្រូវសងសំណងការខូចខាតដែលបានប្រើប្រាក់........................ ៣៤
៣.៤.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណាត្តិ ........................... ៣៥
**៣.៥. ភាតព្វកិច្ចរបស់អាណាត្តិទាយក**............................................................................៣៥
៣.៥.១. ករណីយកិច្ចបង់កម្រៃ ..............................................................................៣៦

៣.៥.២. ករណីយកិច្ចបង់សោហ៊ុយជាមុន ........ ៣៦
៣.៥.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ ........ ៣៧
**៣.៦. ការរំលាយកិច្ចសន្យាអាណត្តិ** ........ ៣៨
៣.៦.១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ ........ ៣៨
៣.៦.១.១. ការបញ្ចប់ដោយការរំលាយកិច្ចសន្យាអាណត្តិដោយភាគី ........ ៣៨
៣.៦.១.២. ការបញ្ចប់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ........ ៣៨
៣.៦.២. អានុភាពនៃការរំលាយ ........ ៣៩

## ជំពូក ៤ កិច្ចសន្យាដឹកជញ្ជូន

**៤.១. សញ្ញាណទូទៅ និង និយមន័យ នៃកិច្ចសន្យាដឹកជញ្ជូន** ........ ៤០
**៤.២. ការដឹកជញ្ជូនទំនិញ** ........ ៤១
**៤.៣. ការដឹកជញ្ជូនអ្នកដំណើរ** ........ ៤២
**៤.៤. ការបញ្ចប់កិច្ចសន្យាដឹកជញ្ជូន** ........ ៤៣
**សេចក្តីសន្និដ្ឋាន** ........ ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ដោយសារតែវិស័យសេដ្ឋកិច្ច និងបច្ចេកវិជ្ជា ការអភិវឌ្ឍឥតឈប់ឈរនាំអោយប្រទេសមួយចំនួនបានផ្លាស់ប្តូរនូវរបបនយោបាយថ្មី ដែលជាចរន្តមួយជំរុញអោយពិភពលោកខិតទៅកាន់តែជិតគ្នាតាមរយៈនយោបាយមួយដែលហៅថា សាកលភាវូបនីយកម្ម។ កត្តានេះបានធ្វើអោយប្រទេសកម្ពុជាយើងរីកចំរើនផងដែរ បន្ទាប់ពីប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមស៊ីវិលរយៈពេលជាងពីរទសវត្សមកនេះ ប្រទេសកម្ពុជាបានខិតខំកសាងនូវហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងកសាងនូវច្បាប់នានា ដើម្បីអនុវត្ត និងទប់ស្កាត់ចំពោះបញ្ហាទាំងឡាយ និងអនុវត្តជាប្រចាំដែលមានដូចជាច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ ច្បាប់រដ្ឋប្បវេណី ច្បាប់រដ្ឋបាល ច្បាប់ពាណិជ្ជកម្មជាដើម។ ជាក់ស្តែងសង្គមត្រូវតែមានច្បាប់ ហើយត្រូវតែធ្វើការផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈដើម្បីអោយពួកគេមានការយល់ដឹង និងមាន សមត្ថភាពក្នុងការគោរពច្បាប់ ហើយសង្គមនិងប្រទេសជាតិក៏ឈានទៅរកភាពរីកចំរើនដែរ។ ដោយទទួលបានការអភិវឌ្ឍខ្លួនបន្តិចម្តងៗ ឈានទៅរកនយោបាយទីផ្សារអន្តរជាតិ ស្របទៅតាមប្រទេសនានានៅលើសកលលោក ធ្វើអោយប្រទេសកម្ពុជារីកចម្រើនទៅមុខដូចជា វិស័យពាណិជ្ជកម្ម។ ជាធម្មតានៅក្នុងវិស័យអាជីវកម្មនេះវាមានទំនាក់ទំនងឯកជន ឬ រដ្ឋ និងការដោះដូរតែងតែប្រើប្រាស់កិច្ចសន្យា ដែលកិច្ចសន្យាទាំងនោះអាចជាកិច្ចសន្យារដ្ឋប្បវេណី ឬកិច្ចសន្យារដ្ឋបាល ឬជាកិច្ចសន្យាសេវាកម្មជាអាទិ៍។ ម៉្យាងទៀតប្រទេសកម្ពុជា បានកែប្រែទម្រង់នូវប្រព័ន្ធសេដ្ឋកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈជាសេដ្ឋកិច្ចទីផ្សារសេរី យ៉ាងណាមិញ ប្រតិបត្តិការដោះដូរទំនិញ និងសេវាកម្មទាំងឡាយត្រូវបានអនុវត្តដោយសេរី និង មានលក្ខណៈស្តង់ដារជាជំហានៗ ហើយសកម្មភាពផ្នែកសេវាកម្មទាំងឡាយបានពង្រីកខ្លួនយ៉ាងសកម្មដែលគួរអោយកត់សម្គាល់។ ជាការពិតណាស់ សកម្មភាពនៃអាជីវកម្មរបស់ក្រុមហ៊ុនអ៊ីអន ( AEON ) ដែលទើបតែបានបើកផ្សារទំនើបធំជាងគេ បានបង្ហាញមុខមាត់យ៉ាងច្បាស់សបញ្ជាក់ឱ្យឃើញថាចរាចរនៃទំនិញ និង សេវាកម្មពិតជាមានសន្ទុះគួរជាទីចាប់អារម្មណ៍។

លើសពីនេះទៅទៀត សកម្មភាពនៃសេវាកម្មទាំងផ្នែករដ្ឋប្បវេណី និង ពាណិជ្ជកម្មមានច្រើនប្រភេទដែលតែងតែកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាជីវភាពអាជីវកម្មផងដែរ។ អាស្រ័យហេតុនេះ ប្រធានបទនៃសារណារបស់យើងខ្ញុំដែលលើកយកមកបរិយាយត្រូវបានកំណត់វិសាលភាពទៅលើកិច្ចសន្យាមួយចំនួន ដូចជា កិច្ចសន្យាម៉ៅការកិច្ចសន្យាបញ្ញើ កិច្ចសន្យាអាណត្តិ និង កិច្ចសន្យាដឹកជញ្ជូន។

មុននឹងឈានទៅដល់ការបកស្រាយអំពី កិច្ចសន្យាសេវាកម្ម ជាដំបូងយើងត្រូវសិក្សាពីពាក្យ សេវាកម្មជាមុនសិន។ វាក្យស័ព្ទ **សេវាកម្ម** នេះមិនបានបង្ហាញនៅក្នុងវចនានុក្រម របស់

សម្តេចសង្ឃរាជ **ជួន ណាត** នោះទេ។ ប៉ុន្តែបើយើងមើលទៅលើច្បាប់ស្តីពី វិធាន និង បញ្ជីពាណិជ្ជកម្មឆ្នាំ ១៩៩៥ និង វិសោធនកម្ម ឆ្នាំ ១៩៩៩ យើងពិតជាឃើញពាក្យ សេវា យ៉ាងជាក់ច្បាស់តែម្តងត្រង់មាត្រា ១ វាក្យខណ្ឌទី៦ ដែលនីតិពន្ធ បានយកវាក្យស័ព្ទ សេវាកម្មនេះទៅប្រើជាមួយពាក្យទំនិញ ដើម្បីកំណត់ខ្លឹមសារដល់ពាក្យពាណិជ្ជកិច្ច។ ម៉្យាងវិញទៀត មាត្រា ១៥៩ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យា ពាណិជ្ជកម្ម ឆ្នាំ ២០១១ យើងក៏បានឃើញវាក្យស័ព្ទ **សេវា** នេះផងដែរ។ អត្ថបទគតិយុត្តដែលកំពុងព្រាងដោយក្រុមអ្នកច្បាប់របស់ក្រសួងពាណិជ្ជកម្មនេះក៏បានផ្តល់អត្ថន័យដល់ពាក្យសេវាដែលសំដៅទៅលើ ភារកិច្ចដែលត្រូវបំពេញជាប្រចាំដោយអ្នកម៉ៅការចំពោះម្ចាស់ការរួមមានដូចជា ការប្រឹក្សា ការថែទាំ ឬ ការជួសជុល។

ដូច្នេះដើម្បីឱ្យមានភាពងាយស្រួល និង កាន់តែច្បាស់ជាងនេះទៅទៀតអំពី ប្រធានបទ **កិច្ចសន្យាសេវាកម្ម** នឹងធ្វើការបកស្រាយ និង ធ្វើការបែងចែកចេញជាបួនជំពូកដូចជា ៖ កិច្ចសន្យាម៉ៅការ ( ជំពូក១ ) កិច្ចសន្យាបញ្ញើ (ជំពូក២ ) កិច្ចសន្យា អាណត្តិ (ជំពូក៣ ) កិច្ចសន្យាដឹកជញ្ជូន (ជំពូក៤ )។

# ជំពូក១ កិច្ចសន្យាម៉ៅការ

ចំពោះកិច្ចសន្យាម៉ៅការ គឺ ជាកិច្ចសន្យាពិសេសមួយនៅក្នុងចំណោមកិច្ចសន្យាទាំង ១១ នៅក្នុងក្រមរដ្ឋប្បវេណី។ នៅក្នុងកិច្ចសន្យាម៉ៅការនេះ នឹងមានការបកស្រាយអំពីនិយមន័យ ក៏ដូចជាទិដ្ឋភាពទូទៅ រួមផ្សំជាមួយ កាតព្វកិច្ចរបស់អ្នកម៉ៅការ និង ម្ចាស់ការ ព្រមទាំងការបញ្ចប់កិច្ច-សន្យានេះផងដែរ។

## ១.១. និយមន័យ និងគោលគំនិត

កិច្ចសន្យាម៉ៅការ សំដៅទៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងមានករណីយកិច្ច សម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាងទៀត មានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ[១]។

កិច្ចសន្យាម៉ៅការ គឺជាកិច្ចសន្យាដែលយកតំលៃថ្នូរ ដែលគូភាគីនៃកិច្ចសន្យាត្រូវផ្តល់តាវកាលិកអោយគ្នាទៅវិញទៅមក។ គោលគំនិតសំខាន់នៃកិច្ចសន្យាម៉ៅការ គឺសង្កត់ធ្ងន់នៅត្រង់ថា អ្នកម៉ៅការត្រូវធ្វើការដើម្បីសម្រេចការងារណាមួយ។

កិច្ចសន្យាម៉ៅការនេះមានច្រើនប្រភេទណាស់ ដូចជា កិច្ចសន្យាសង់នាវា កិច្ចសន្យាបោកអ៊ុត កិច្ចសន្យាជួសជុល កិច្ចសន្យាធ្វើបាបកថា កិច្ចសន្យាដឹកជញ្ជូន កិច្ចសន្យាម៉ៅការសាងសង់ជាដើម។ បញ្ជាក់ កិច្ចសន្យាម៉ៅការ ចាំបាច់មានកម្រៃចំពោះការធ្វើការងារ ហេតុដូច្នេះ ឧទាហរណ៍ កិច្ចសន្យាធ្វើបាបកថាដោយមិនយកកម្រៃវិញ តាមនិយមន័យ ពុំមែនជាកិច្ចសន្យាម៉ៅការទេ។

ជាឧទាហរណ៍ គួរកត់សំគាល់ថា កិច្ចសន្យាម៉ៅការមានអត្ថន័យខុសគ្នា នឹងកិច្ចសន្យាអាណត្តិ ក៏ដូចជាកិច្ចសន្យាការងារផងដែរ។ ភាពខុសគ្នាមានដូចខាងក្រោម ៖

នៅក្នុងកិច្ចសន្យាការងារ ខ្លឹមសារនៃកិច្ចសន្យា គឺថានិយោជិត សន្យាថានឹងធ្វើពលកម្ម ហើយនិយោជក សន្យាថានឹងផ្តល់ប្រាក់ឈ្នួល ទៅលើកិច្ចការពលកម្មនោះ។ និយោជិតពុំចាំបាច់សម្រេចកិច្ចការងាររបស់ខ្លួនទេ ដែលជាលក្ខណៈខុសគ្នាទៅនឹងកិច្ចសន្យាម៉ៅការ។

នៅក្នុងកិច្ចសន្យាអាណត្តិ អាណត្តិគាហក ត្រូវចាត់ចែងកិច្ចការ ដែលត្រូវបានផ្តល់អាណត្តិអោយដោយអាណត្តិទាយក ហើយអាណត្តិគាហក មិនចាំបាច់ដាច់ខាតត្រូវតែសម្រេចកិច្ចការនោះទេ ដែលនេះជាចំនុចខុសគ្នាពីកិច្ចសន្យាម៉ៅការដែរ។

## ១.២. លក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការពុំមានទាមទារលក្ខខណ្ឌពិសេសណាមួយទេ គឺអោយតែគូភាគីមានការព្រមព្រៀងជាការគ្រប់គ្រាន់នឹងបង្កើតកិច្ចសន្យាបានហើយ។

---

[១] មាត្រា ៦៥២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា[២]។ នេះបង្ហាញអោយឃើញថា ការបង្កើតកិច្ចសន្យាម៉ៅការមិនមានលក្ខណៈពិបាកនោះទេ ដោយគ្រាន់តែមានការព្រមព្រៀងត្រូវគ្នារវាងម្ចាស់ការ និង អ្នកម៉ៅការ ពោលគឺ ម្ចាស់ការ និង អ្នកម៉ៅការមានសំណើរ និង ស្ទីការត្រូវគ្នា។

## ១.៣. ពេលដែលត្រូវបង់កម្រៃ

កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ។ បើពុំចាំបាច់ក្នុងការប្រគល់វត្ថុទេ ក្រោយពីបានសម្រេចការងារហើយ អ្នកម៉ៅការអាចទាមទារអោយបង់កម្រៃបាន[៣]។

ក្នុងករណីដែលអ្នកម៉ៅការចាំបាច់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ កម្រៃត្រូវបង់ព្រមជាមួយគ្នា នឹងពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ហើយក្នុងករណីដែលមិនចាំបាច់ប្រគល់វត្ថុទេ អ្នកម៉ៅការអាចទាមទារអោយបង់កម្រៃបានក្រោយពេលបានសម្រេចការងារ។ មានន័យថា ប្រសិនបើអ្នកម៉ៅការបានសម្រេចការងាររួចរាល់ហើយ ដូច្នេះអ្នកម៉ៅការគឺត្រូវការលុយពីម្ចាស់ការ ដែលជាតាវកាលិកតបស្នងទៅនឹងកម្មវត្ថុនៃការងារដែលបានធ្វើ ពោលគឺអ្នកម៉ៅការមិនអាចអោយម្ចាស់ការបង់លុយផ្តាច់អោយខ្លួនបានទេ ប្រសិនបើមិនទាន់សម្រេចការងារដែលជាកម្មវត្ថុនៃការងារបានជោគជ័យ។ ប៉ុន្តែជាទូទៅ អ្នកម៉ៅការមួយចំនួនគឺពុំមានធនធានគ្រប់គ្រាន់ក្នុងការបង់សោហ៊ុយជាមុនទាំងអស់ដើម្បីបំពេញការងារអោយបានជោគជ័យនោះទេ ពោលគឺតម្រូវអោយម្ចាស់ការធ្វើការបង់ប្រាក់ជាដំណាក់កាល ដែលជាលក្ខណៈមួយក្នុងការជួយសម្រួលធនធានខ្លះៗដល់អ្នកម៉ៅការ។ ម្យ៉ាងទៀត ការជួយសម្រួលដល់អ្នកម៉ៅការដោយម្ចាស់ការបែបនេះ ក៏សបញ្ជាក់ថានេះជាការយោគយល់អធ្យាស្រ័យគ្នារវាងអ្នកម៉ៅការ និងម្ចាស់ការ។ មួយវិញទៀតការជួយផ្តល់ធនធានខ្លះៗនេះដល់អ្នកម៉ៅការ ក៏ជាការធានាមួយរបស់ម្ចាស់ការ ដើម្បីធ្វើអោយអ្នកម៉ៅការទុកចិត្ត ព្រោះជាទូទៅ អ្នកម៉ៅការតែងតែបារម្ភថា តើម្ចាស់ការច្បាស់ជានឹងបង់កម្រៃអោយខ្លួនឬទេនៅពេលដែលសម្រេចការងារ ដែលនេះ គឺជាក្តីបារម្ភធំបំផុតរបស់ម្ចាស់ការ។ តាមធម្មតា ជាឧទាហរណ៍ ក្នុងករណីម៉ៅការសាងសង់ផ្ទះ ភាគច្រើនធ្វើកិច្ចព្រមព្រៀងបង់កម្រៃម្តងពេលចាប់ផ្តើមសាងសង់ ម្តងទៀតពេលធ្វើគ្រោងផ្ទះ និង កម្រៃដែលនៅសល់ត្រូវបង់នៅពេលសាងសង់រួចជាស្ថាពរ។ ចំពោះការព្រមព្រៀងបែបនេះ ឬ ការព្រមព្រៀងផ្សេងពីនេះគឺអាស្រ័យទៅលើការចរចារ ឬព្រមព្រៀងដោយពិតប្រាកដ រវាងម្ចាស់ការ និង អ្នកម៉ៅការ។

[២] មាត្រា ៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៣] មាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.៤. កាតព្វកិច្ចរបស់ម្ចាស់ការ

ចំពោះកាតព្វកិច្ចរបស់ម្ចាស់ការ មិនមានលក្ខណៈស្មុគស្មាញ និង ច្រើនពេកទេ ពោលគឺមានតែ ២ សម្រាប់ម្ចាស់ការដែលត្រូវអនុវត្តដែលដំបូងគឺ កាតព្វកិច្ចបង់កម្រៃ និងមួយទៀតគឺ ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា។

#### ១.៤.១. កាតព្វកិច្ចបង់កម្រៃ

ម្ចាស់ការត្រូវបង់កម្រៃផ្តាច់អោយទៅអ្នកម៉ៅការ ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ[៤]។ ជាក់ស្តែងដូចជា ការម៉ៅការសាងសង់ ម្ចាស់ការ ត្រូវបង់កម្រៃនៅពេលដែលអ្នកម៉ៅការបានសម្រេចការងាររួចរាល់ជាស្ថាពរ ដូចដែលបានព្រមព្រៀងនៅក្នុងកិច្ចសន្យាម៉ៅការសាងសង់។ គូភាគី មានសិទ្ធិសេរីភាពក្នុងការបង្កើតកិច្ចព្រមព្រៀងពិសេស ដែលទាក់ទងទៅនឹងការបង់កម្រៃ ពេលវេលានៃការបង់កម្រៃ ទីកន្លែងនៃការបង់កម្រៃជាដើម ព្រោះ វាមិនមែនជាបញ្ញត្តិដែលត្រូវអនុវត្តដោយបង្ខំនោះទេ។

#### ១.៤.២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា

ម្ចាស់ការមានករណីយកិច្ចទទួលនូវវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យា ក្រោយពេលដែលអ្នកម៉ៅការបានសម្រេចការងាររបស់ខ្លួន។ ប្រសិនបើម្ចាស់ការ មិនបានទទួលវត្ថុ ដោយមានកំហុស នោះគាត់ទទួលបន្ទុកកាតព្វកិច្ចនៅក្នុងករណីការយឺតយ៉ាវក្នុងការទទួល។ មានន័យថា ម្ចាស់ការត្រូវតែទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាជាដាច់ខាត។ ការមិនខ្វល់ ការមិនទទួលយក របស់ម្ចាស់ការ អាចនឹងមានការខូចខាតកើតឡើង ដូច្នេះនេះជាបន្ទុករបស់ម្ចាស់ការជាអ្នកទទួលខុសត្រូវ។

យោងតាមមាត្រា ៤៥៦ កថាខណ្ឌ១ បានចែងថា ក្នុងករណីដែលម្ចាស់បំណុលប្រកែកជាមុននូវការទទួលការសង ឬករណីដែលកូនបំណុលបានស្នើផ្តល់ការសង តែម្ចាស់បំណុលមិនទទួលការសងនោះដោយមានកំហុស កូនបំណុលអាចទាមទារពីម្ចាស់បំណុលនូវសំណងនៃការខូចខាត ដែលបណ្តាលមកពីការមិនទទួលនោះបាន។

### ១.៥. កាតព្វកិច្ចរបស់អ្នកម៉ៅការ

ចំពោះកាតព្វកិច្ចរបស់អ្នកម៉ៅការ ដែលសំខាន់មានពីរ គឺ ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ និង ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ។

#### ១.៥.១. ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ

នៅក្នុងចំនុចនេះ នឹងមានការបកស្រាយអំពីគោលបំណង ដែលទាក់ទងនឹង ករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈ ព្រមទាំងមានការលើកឧទាហរណ៍មកបញ្ជាក់ឱ្យមានលក្ខណៈកាន់តែច្បាស់លាស់ថែមទៀតផងដែរ។

[៤] មាត្រា ៦៥៣ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ១.៥.១.១. គោលគំនិត

អ្នកម៉ៅការមានករណីយកិច្ចសម្រេចការងារ ដោយគ្មានវិការៈចំពោះម្ចាស់ការ[៥]។ដូច្នេះ ការទទួលខុសត្រូវដែលអ្នកម៉ៅការត្រូវទទួលបន្ទុកក្នុងករណីដែលការងារនោះមានវិការៈ គឺជាប្រភេទមួយនៃការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។

តាមស្មារតីនៃមាត្រា ៦៥៤ កថាខណ្ឌទី ២ និង ទី ៣ បានកំណត់ថាលក្ខខណ្ឌដែលចាត់ទុកជាការងារមានវិការៈមានដូចជា ៖

- ការងារពុំមានលក្ខណៈដូចបានព្រមព្រៀង
- ការងារពុំត្រឹមត្រូវតាមគោលដៅក្នុងការប្រើប្រាស់ដែលបានកំណត់នៅក្នុងកិច្ចសន្យា
- ការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតី
- ការងារដែលបានធ្វើមិនគ្រប់ចំនួន ឬ
- អ្នកម៉ៅការបានធ្វើការផ្ទុយនឹងការបញ្ជា

ជាទូទៅ ខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺសម្រេចការងារដែលមានលក្ខណៈជាក់លាក់។

ឧទាហរណ៍ ម្ចាស់ការអោយជាងគំនូរគូររូបរបស់ខ្លួន ដូចនេះគេមិនអាចនិយាយបានទេថា ការងារ គឺ អនុលោមទៅតាមលក្ខណៈដែលបានព្រមព្រៀង ប្រសិនបើគំនូរនោះ មិនដូចនឹងម្ចាស់ការ។

ឧទាហរណ៍មួយទៀត គឺថាអ្នកម៉ៅការ បានសង់អាគារដោយផ្អែកលើកិច្ចសន្យាថា ម្ចាស់ការ នឹងប្រើប្រាស់អាគារនោះ សម្រាប់បើកជាសណ្ឋាគារ ប៉ុន្តែអ្នកម៉ៅការមិនបានបំពាក់ប្រព័ន្ធបង្ហូរទឹកសំអុយចេញ។ ក្នុងករណីនេះការងារដែលបានសម្រេចរួច គឺមិនស្របទៅនឹងការប្រើប្រាស់ដែលបានសន្មតនៅក្នុងកិច្ចសន្យា។

ម្យ៉ាងវិញទៀត ជាឧទាហរណ៍ ម្ចាស់ការបាន អោយអ្នកម៉ៅការធ្វើតុ សម្រាប់ដាក់ទូរទស្សន៍ ដោយមិនបានកំណត់ពីវិធី ដែលត្រូវប្រើប្រាស់ ហើយបន្ទាប់មក តុនោះបានបាក់បែកនៅពេលដែលដាក់ទូរទស្សន៍នៅពីលើតុនោះ។ នេះគឺវាមិនឆ្លើយតបទៅនឹង ការងារត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីនោះទេ។

ក្នុងករណីនៃកិច្ចសន្យា ម៉ៅការសាងសង់អាគារ ដែលបានព្រមព្រៀងលាបជញ្ជាំងពណ៌ពងមាន់ តែប្រសិនបើលាបពណ៌សទៅវិញ ទោះបីជាពណ៌សក៏ដោយ ពណ៌ពងមាន់ក៏ដោយ ក៏គ្មានបញ្ហាអ្វីដែរក្នុងការរស់នៅ ប៉ុន្តែពុំមានលក្ខណៈដូចកិច្ចព្រមព្រៀងទេ ដូច្នេះហើយត្រូវចាត់ទុកជាការងារមានវិការៈ។ ម្យ៉ាងទៀត ក្នុងករណីដែលម្ចាស់ការ បានបញ្ជាអោយហាងខោអាវកាត់

[៥] មាត្រា ៦៥៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ខោ តែបែរជាគេកាត់សំពត់ទៅវិញ នេះបង្ហាញអោយឃើញថា លក្ខណៈនៃការងារមានគម្លាតយ៉ាងខ្លាំងពីកិច្ចសន្យា ដែលច្បាស់មិនអាចទទួលស្គាល់ថា ជាការអនុវត្តកិច្ចសន្យាទាល់តែសោះ ការងារនោះក៏មានវិការៈដែរ។

**១.៥.១.២. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ក្នុងករណីដែលការងារមានវិការៈ**

ក្នុងករណីដែលអ្នកម៉ៅការ បំពេញការងារដោយមានវិការៈ ម្ចាស់ការមានសិទ្ធិទាមទារឱ្យអ្នកម៉ៅការ ធ្វើការអនុវត្តអោយបានត្រឹមត្រូវតាមកិច្ចសន្យា ឬ ជ្រើសរើសវិធីណាមួយតាមការអនុញ្ញាតរបស់ក្រមរដ្ឋប្បវេណី។ សិទ្ធិទាមទារនេះត្រូវយកមកអនុវត្តនៅក្នុងកំឡុងពេលមួយឆ្នាំដែលផ្តើមគណនាចាប់ពីពេល ដែលម្ចាស់ការបានដឹង ឬ គួរបានដឹងអំពីអត្ថិភាពនៃវិការៈនោះ (យោងតាមស្មារតី នៃមាត្រា៦៦១)។

មានន័យថាកំឡុងពេលនៃការប្រើសិទ្ធិ មួយឆ្នាំនេះគឺសំដៅទៅលើសិទ្ធិទាមទារអោយអនុវត្តការងារពេញលេញ សិទ្ធិទាមទារសោហ៊ុយជួសជុល ជាអាទិ៍ សិទ្ធិរំលាយកិច្ចសន្យា សិទ្ធិទាមទារអោយបន្ថយតម្លៃរបស់ម្ចាស់ការ។ រយៈពេលមួយឆ្នាំនេះគឺគ្មានពាក់ព័ន្ធទៅនឹងខ្លឹមសារនៃការងារទេ។ កំឡុងពេលនេះ ត្រូវគិតចាប់ពីពេលដែលម្ចាស់ការបានដឹងថា មានវិការៈ ឬ ពីពេលដែលត្រូវដឹងអំពីវិការៈនោះដោយយកពេលណាមួយមុនគេ មកធ្វើជាមូលដ្ឋានក្នុងការគណនា ដែលមានន័យថាមិនមែនជាពេលដែលបានប្រគល់កម្មវត្ថុនៃការងារ ឬ ពេលដែលបានបញ្ចាក់ការងារនោះទេ។

ក្នុងករណីដែលអ្នកម៉ៅការបានដឹងហើយ អំពីវិការៈនៃការងារ តែបែរមិនបានរាយការណ៍ប្រាប់ម្ចាស់ការ ក្នុងករណីនេះ មិនអាចអោយអ្នកម៉ៅការរួចផុតពីកាតព្វកិច្ចបានឡើយ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬ កម្រិតការទទួលខុសត្រូវក៏ដោយ (យោងតាមស្មារតី នៃមាត្រា ៦៦២)។

មានន័យថា ដោយផ្អែកទៅលើគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា ភាគីនៃកិច្ចសន្យាម៉ៅការ អាចធ្វើការសន្យាពិសេស ដែលបំបាត់ចោល ឬ កម្រិតពីការទទួលខុសត្រូវ របស់អ្នកម៉ៅការបានដោយសេរី ប៉ុន្តែមិនអាចទទួលស្គាល់នូវការបំបាត់ចោល ឬ កម្រិតពីការទទួលខុសត្រូវបានឡើយ ក្នុងករណីដែលអ្នកម៉ៅការពុំបានរាយការណ៍អំពីវិការៈដែលខ្លួនបានដឹង។

**គ. ការទាមទារអោយអនុវត្តការងារពេញលេញរបស់ម្ចាស់ការ**

យោងតាមមាត្រា ៦៥៥ បើរកឃើញថាការងារមានវិការៈ ម្ចាស់ការអាចទាមទារអោយអ្នកម៉ៅការបំពេញកិច្ចការរបស់ខ្លួនអោយបានពេញលេញ ដោយកំណត់កំឡុងពេលសមរម្យបាន [៦]។

[៦] មាត្រា ៦៥៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ក្នុងករណីនេះអ្នកម៉ៅការអាចជួសជុសវិការៈ នៃការងារនោះ ឬ អាចធ្វើការងារនោះសារជាថ្មីឡើងវិញ ដោយផ្អែកតាមការជ្រើសរើសបាន។

ចំពោះមាត្រានេះ ចែងអំពីការទាមទារ អោយអនុវត្តការងារពេញលេញ ក្នុងករណីដែលការងារមានវិការៈ។ ការអនុវត្តការងារពេញលេញ ដែលប្រើក្នុងនេះ មានន័យថាជាទស្សនៈមួយរួមទាំងការជួសជុសនូវវិការៈ និង ការធ្វើការងារឡើងវិញ។ ម្យ៉ាងទៀតការផ្តល់នូវជម្រើសស្តីពីការដកវិការៈចេញ ទៅអ្នកម៉ៅការ ក្នុងករណីដែលការងារមានវិការៈ ហើយប្រសិនជាអ្នកម៉ៅការមានបំណងចង់ធ្វើការងារឡើងវិញ ជាគោលការណ៍ បញ្ញត្តិនេះអនុញ្ញាតអោយធ្វើឡើងវិញ។

ជាឧទាហរណ៍ ក្នុងករណីដែលបានអោយកាត់ខោអាវសម្រាប់រដូវរងា តែបែរជាកាត់ខោអាវសម្រាប់រដូវក្តៅទៅវិញ។ ការកែខោអាវសម្រាប់រដូវក្តៅ អោយទៅជាខោអាវសម្រាប់រដូវរងារ មិនអាចធ្វើបាន ឬ ត្រូវការពេលវេលាច្រើនណាស់។ ក្នុងករណីនេះការកាត់ថ្មីជាការងាយស្រួលជាង ហេតុនេះហើយ បញ្ញត្តិនេះត្រូវផ្តល់ជម្រើសធ្វើជាថ្មី។

ក្នុងករណីការអនុវត្តការងារពេញលេញ ត្រូវចំណាយសោហ៊ុយច្រើនហួលហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ អ្នកម៉ៅការអាចបដិសេធចំពោះការអនុវត្តការងារពេញលេញបាន [៧]។ នៅក្នុងករណីនេះ ម្ចាស់ការ មិនអាចទាមទារអោយសងចំណាយលើការជួលជុស នៅក្រោយការបញ្ចប់ការជួសជុលដោយខ្លួនឯងនោះទេ (មាត្រា ៦៥៦ កថាខណ្ឌ៤) និង មិនអាចទាមទារសំណងនៃការខូចខាត ដែលបណ្តាលមកពីការជួសជុលរបស់ខ្លួននោះទេ (មាត្រា ៦៥៩ កថាខណ្ឌ២)។ ដូច្នេះប្រសិនបើការអនុវត្តការងារពេញលេញ ចាំបាច់ចំណាយសោហ៊ុយច្រើនហួសហេតុ ដោយប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈ នោះម្ចាស់ការត្រូវទទួលរងនូវហានិភ័យនេះ។ ប្រសិនបើម្ចាស់ការចង់ជៀសវាងនូវស្ថានភាពហានិភ័យបែបនេះ គាត់ចាំបាច់ត្រូវបង្កើតកិច្ចព្រមព្រៀងពិសេសជាមួយនឹងអ្នកម៉ៅការ។

ជាឧទាហរណ៍ ក្នុងករណីដែលការសាងសង់អាគារ ហើយត្រូវប្រើក្បឿងសម្រាប់ប្រក់ជាដំបូល ក៏ប៉ុន្តែក្នុងនោះមានក្បឿងមួយដែលច្រឡំពណ៌ខុសផ្សេងពីគេ។ ក៏ប៉ុន្តែ ក្នុងករណីនេះប្រសិនបើប្តូរក្បឿងដែលមានពណ៌ខុសគេនោះ តាមបច្ចេកទេស ត្រូវរុះរើដំបូលទាំងអស់ចេញសិនហើយត្រូវធ្វើអោយអស់សោហ៊ុយយ៉ាងច្រើនផង។ ក្បឿងមួយដុំពណ៌ខុសគេមិនមែនជាវិការៈធ្ងន់ធ្ងរទេ គ្រាន់តែមិនសូវល្អមើលបន្តិចតែប៉ុណ្ណោះ។ ថែមទាំងចំណាយសម្រាប់ការជួសជុសច្រើនជ្រុលមិនសមរម្យនឹងទម្ងន់នៃវិការៈផង។ ក្នុងករណីនេះមិនអាចទាមទារអោយជួសជុសឡើងវិញទេ។

[៧] មាត្រា ៦៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ជាងនេះទៅទៀត បើសិនអ្នកម៉ៅការចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការអាចទាមទារអោយម្ចាស់ការសងការងារដែលមានវិការៈនោះមកវិញបាន(មាត្រា ៦៥៥ កថាខណ្ឌ៣)។

មានន័យថា បើសិនជាអ្នកម៉ៅការសម្រេចចិត្តថា នឹង ធ្វើការងារនោះសាជាថ្មី ដូច្នេះវត្ថុចាស់ដែលមានវិការៈនោះ ត្រូវតែប្រគល់មកអោយអ្នកម៉ៅការវិញជាដាច់ខាត។

**ខ. ការជួសជុលវិការៈដោយម្ចាស់ការ**

នៅក្រោយពេលដែលកំឡុងពេលសមរម្យដែលបានកំណត់ ដើម្បីអនុវត្តការងារអោយបានពេញលេញនោះ បានកន្លងផុតហើយ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ លើការជួសជុលវិការៈនោះ ពីអ្នកម៉ៅការបាន[៨]។ ប្រសិនបើ ការងារមានវិការៈ ម្ចាស់ការចាំបាច់ដាស់តឿនអោយអនុវត្តការងារអោយពេញលេញ ដោយកំណត់កំឡុងពេលជាក់លាក់ជាមុនសិន។ ហើយបន្ទាប់មក ប្រសិនបើអ្នកម៉ៅការមិនបានអនុវត្តការងារអោយបានពេញលេញនោះទេ នៅក្នុងកំឡុងពេលនោះ ម្ចាស់ការអាចធ្វើការជួសជុសវិការៈដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយចាំបាច់លើការជួសជុលវិការៈនោះវិញ។

ជាឧទាហរណ៍ ក្នុងករណីដែលម្ចាស់ការបានអោយអ្នកម៉ៅការធ្វើរបងព័ទ្ធជុំវិញផ្ទះ ក៏ប៉ុន្តែរបងនោះស្រាប់តែប្រេះបន្ទាប់ពីសាងសង់រួច ម្ចាស់ការអាចដាស់តឿនអោយអ្នកម៉ៅការសាងសង់អោយអនុវត្តការងារពេញលេញ ដោយកំណត់កំឡុងពេលសមរម្យមួយ តែប្រសិនបើអ្នកម៉ៅការពុំបានអនុវត្តការងារពេញលេញ ទោះបីជាកំឡុងពេលនោះកន្លងផុតទៅក៏ដោយ នោះម្ចាស់ការអាចជួសជុលកន្លែងដែលប្រេះនោះដោយខ្លួនឯងបាន ឬ អាចជួលជាងផ្សេងទៀតជាអាទ៍ ដើម្បីជួសជុល ក្នុងការណីនេះម្ចាស់ការអាចទាមទារសោហ៊ុយពីអ្នកម៉ៅការបាន។

ក្នុងករណីដែលការអនុវត្តការងារអោយពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ នឹងធ្វើអោយមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯង ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈ ពីអ្នកម៉ៅការបាន[៩]។ បញ្ជាក់ ៖ ក្នុងករណីដែលម្ចាស់ការ ដែលត្រូវអ្នកម៉ៅការបដិសេធការអនុវត្តការងារពេញលេញនោះ ហើយបានជួសជុលដោយខ្លួនឯង ឬ បានពឹងអោយជាងផ្ទះផ្សេងទៀតជួសជុលវិការៈនោះ ក្នុងករណីនេះអ្នកម៉ៅការមិនអាចបដិសេធនូវការទាមទារសោហ៊ុយ ហើយអ្នកម៉ៅការត្រូវបង់ជាប្រាក់នូវសោហ៊ុយទាំង

[៨] មាត្រា ៦៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៩] មាត្រា ៦៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

នេះ មិនថាមានទំហំច្រើនយ៉ាងណាក៏ដោយ។ ចំនុចនេះវាមានលក្ខណៈមិនស៊ីសង្វាក់គ្នាទៅនឹង កថាខណ្ឌ២ នៃមាត្រា ៦៥៥។ ដូច្នេះហើយបានជាកថាខណ្ឌ៤ នៃមាត្រា ៦៥៦ បានចែងថា បញ្ញត្តិនៃកថាខណ្ឌទី ១ ទី ២ និង ទី ៣ ខាងលើនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកម៉ៅការបានបដិសេធការអនុវត្តការងារពេញលេញ យោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា ៦៥៥ (ការទាមទារអោយអនុវត្តការងារពេញលេញ)។

### គ. សិទ្ធិរំលាយរបស់ម្ចាស់ការ

ប្រសិនបើ ការងារមានវិការៈ ម្ចាស់ការ អាចប្រើសិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកតាមបញ្ញត្តិ នៃផ្នែកទី ៤ ជំពូកទី ៤ នៃគន្ថីទី ៤ បាន[១០] ( ការរំលាយកិច្ចសន្យា )។ មួយវិញទៀតម្ចាស់ការអាចរំលាយកិច្ចសន្យាម៉ៅការបាន តែក្នុងករណីដែលវិការៈនោះត្រូវនឹង **ការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ**។ ទន្ទឹមនឹងនេះដែរ ប្រសិនបើការអនុវត្តការងារអោយបានពេញលេញ មិនអាចធ្វើទៅបាន ឬ ប្រសិនបើការអនុវត្តការងារអោយបានពេញលេញ អាចធ្វើទៅបាន ប៉ុន្តែត្រូវចំណាយពេលវេលាយូរ ដូច្នេះ គេអាចនិយាយថាវិការៈនៃការងារនោះ គឺជាការបំពានកាតព្វកិច្ចធ្ងន់ធ្ងរ។

ជាមួយគ្នានេះដែរ ប្រសិនបើក្នុងករណីដែល ការអនុវត្តការងារអោយពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការនឹងធ្វើអោយខូចខាត ផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការនោះម្ចាស់ការអាចរំលាយកិច្ចសន្យាបានដោយបញ្ញត្តិតាម(មាត្រា ៦៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២)។

ក៏ប៉ុន្តែ បញ្ញត្តិខាងលើ មិនត្រូវយកមកអនុវត្តចំពោះអាគារ ឬ សំណង់លើដីផ្សេងទៀតបានទេ។ ប្រសិនបើ ម្ចាស់ការត្រូវបានអនុញ្ញាតអោយរំលាយកិច្ចសន្យាម៉ៅការ ដែលកំណត់ថាអ្នកម៉ៅការត្រូវសង់អាគារ ឬ សំណង់លើដីផ្សេងទៀត ហើយដោយសារតែវិការៈ អ្នកម៉ៅការត្រូវរុះរើអាគារចេញ នៅក្រោយការរំលាយ ទោះបីជាអាគារនោះត្រូវបានសាងសង់ហើយក៏ដោយ។ វាគឺជាបន្ទុកមួយដ៏ធ្ងន់ធ្ងរចំពោះអ្នកម៉ៅការ ហើយ និង ធ្វើអោយខាតបង់ដល់វិស័យសេដ្ឋកិច្ចផងដែរ។ ដូច្នេះ ក្នុងករណីនេះ ម្ចាស់ការមិនអាចរំលាយកិច្ចសន្យាបានទេ ទោះបីជាការងារមានវិការៈក៏ដោយ ប៉ុន្តែម្ចាស់ការអាចទាមទារបាន តែការអនុវត្តការងារអោយបានពេញលេញ ឬ សំណងនៃការខូចខាតតែប៉ុណ្ណោះ។ ជាមួយគ្នានេះផងដែរ ប្រសិនបើសំណង់នោះ ពុំមានតម្លៃនឹងប្រើប្រាស់ចំពោះម្ចាស់ការ ដោយសារតែវិការៈនោះ វាធ្ងន់ធ្ងរពេក នោះម្ចាស់ការអាចរំលាយកិច្ចសន្យាបាន( មាត្រា ៦៥៧ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២ )។

[១០] មាត្រា ៦៥៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ជាឧទាហរណ៍ ក្នុងករណីដែល ម្ចាស់ការ អោយអ្នកម៉ៅការ សាងសង់ផ្ទះ ប៉ុន្តែបន្ទាប់ពីសាងសង់រួច តាមបច្ចេកទេស ក៏សង្កេតឃើញថា ផ្ទះនោះមានគ្រឹះមិនពេញលក្ខណៈ ការសាងសង់មិនត្រឹមត្រូវទាំងស្រុងតាមស្តង់ដាបច្ចេកទេស ឬ ការប្រើប្រាស់គ្រឿងសំណង់មិនមានគុណភាពល្អផ្សេង ៗ ជាអាទិ៍ ហើយបើព្យាករណ៍ទុកឃើញថា មានគ្រោះថ្នាក់រហូតដល់អាគារនោះរលំបែកបាក់ប្រសិនបើមិនរុះអាគារនោះចេញ។ ហើយតាមស្ថានភាពបែបនេះ អាគារនេះមានវិការៈធ្ងន់ធ្ងរ និងមិនអាចប្រើប្រាស់បានជាដាច់ខាត ពោលគឺ មានតែសាងសង់ថ្មីទើបអាចប្រើប្រាស់បានដោយសារតែអាគារនោះពុំមានតម្លៃនឹងប្រើប្រាស់ទៀត។ ដូច្នេះហើយ ការរុះរើ ក៏ ដូចជាសាងសង់ថ្មីនោះមិនចាត់ទុកថា គឺជាការខ្ជះខ្ជាយនោះទេ ព្រោះវិការៈនៃអាគារនេះ មានលក្ខណៈធ្ងន់ធ្ងរខ្លាំងណាស់។ ម្យ៉ាងទៀត ការទទួលស្គាល់អោយរំលាយកិច្ចសន្យា ហើយអោយសងថ្លៃសាងសង់ ឬ ទទួលបន្ទុកនូវសោហ៊ុយ សម្រាប់ធ្វើការបដិទានឡើងវិញ គឺជាការកំណត់មួយដែលមិនទុកអោយអ្នកម៉ៅការបដិសេធបានឡើយ។

### ឃ. សិទ្ធទាមទារអោយបន្ថយថ្លៃរបស់ម្ចាស់ការ

នៅក្រោយពេលដែលកំឡុងពេលសមរម្យដែលបានកំណត់ ដើម្បីអនុវត្តការងារអោយពេញលេញនោះ បានកន្លងផុតហើយ ម្ចាស់ការអាចទាមទារអោយបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងករណីដែលអនុវត្តការងារអោយពេញលេញ មិនបានសម្រេច ឬ ក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ នឹងធ្វើអោយមានការខូចខាតប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការ[១១] ។

កម្រៃនឹងត្រូវបន្ថយចុះ តាមការទាមទារអោយបន្ថយថ្លៃ យោងតាមសមាមាត្រនៃតម្លៃការងារដែលមានភ្ជាប់នូវវិការៈ ជាមួយនឹងតម្លៃនៃការងារដែលគ្មានវិការៈនោះ[១២]។

នៅក្នុងករណីនេះគឺចង់សំដៅថា ម្ចាស់ការមិនចាំបាច់ធ្វើរហូតដល់រំលាយកិច្ចសន្យានោះទេ គឺម្ចាស់ការអាចបន្ថយថ្លៃក្នុងការបង់ទៅអោយអ្នកម៉ៅការក៏បានដែរ។ ម្យ៉ាងទៀត ដើម្បីសម្របសម្រួលនូវទំនាក់ទំនងរវាងការអនុវត្តការងារពេញដោយអ្នកម៉ៅការ និង សិទ្ធិទាមទារបន្ថយតម្លៃរបស់ម្ចាស់ការ ជាគោលការណ៍ ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការ មានអាទិភាពជាងប៉ុន្តែ ប្រសិនបើការអនុវត្តការងារពេញលេញនោះ នឹង ធ្វើអោយខូចប្រយោជន៍ដល់ម្ចាស់ការ នោះ

[១១] មាត្រា ៦៥៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[១២] មាត្រា ៦៥៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

មានន័យថា សិទ្ធិទាមទារអោយបន្ថយថ្លៃរបស់ម្ចាស់ការគឺមានអាទិភាពជាងវិញ ពោលគឺម្ចាស់ការអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីបន្ថយតម្លៃរបស់អ្នកម៉ៅការបាន។

ចំពោះការគណនាប្រាក់ដែលត្រូវបន្ថយ។ ជាឧទាហរណ៍ ប្រសិនបើតម្លៃនៃការម៉ៅការស្មើនឹង ២០០០ ដុល្លា។ ហើយការងារដែលធ្វើនោះគឺ សន្មតថាមានវិការៈ ៥០ % នៃការងារទាំងអស់។ ហើយប្រសិនបើ ការអនុវត្តការងារពេញលេញនោះ ធ្វើអោយខូចប្រយោជន៍ដល់ម្ចាស់ការ ដូច្នេះម្ចាស់ការអាចប្រើសិទ្ធិទៅលើការបន្ថយថ្លៃបាន។ ដោយសារតែមានវិការៈ ៥០% ដូច្នេះម្ចាស់ការអាចបន្ថយថ្លៃ ៥០% នៃថ្លៃសរុបបាន។ ដូច្នេះម្ចាស់ការអាចបង់អោយអ្នកម៉ៅការ ១០០០ ដុល្លា ដែលមានន័យថា ប្រាក់ដែលត្រូវបន្ថយគឺ ១០០០ ដុល្លា។

### ខ. សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ

ការទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ ត្រូវតែផ្អែកលើបញ្ញត្តិទូទៅនៃសំណងការខូចខាត ឬ អនុវត្តសិទ្ធិរបស់ខ្លួន ដែលមានចែងចាប់ពីមាត្រា ៦៥៥ ដល់ ៦៥៨ នៃក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧។ ម្ចាស់ការអាចទាមទារសំណងនៃការខូចខាត ពីអ្នកម៉ៅការ ជំនួសអោយការអនុវត្តការងារពេញលេញ បានតែក្នុងករណីដូចជា កំឡុងពេលសមរម្យមួយសម្រាប់អ្នកម៉ៅការអនុវត្តការងារនោះបានកន្លងផុតទៅ ឬ ការអនុវត្តការងារពេញលេញរបស់អ្នកម៉ៅការ មិនបានសម្រេច ឬ ករណីដែលវាយតម្លៃថា ការអនុវត្តការងារពេញលេញដោយអ្នកម៉ៅការនោះ នឹង ធ្វើអោយខូចខាតផលប្រយោជន៍ ដោយមិនត្រឹមត្រូវចំពោះអ្នកម៉ៅការ។ ជាមួយគ្នានេះផងដែរ ប្រសិនបើម្ចាស់ការចង់ទាមទារនូវសំណងនៃការខូចខាត គាត់ត្រូវទាមទារអោយអនុវត្តពេញលេញជាមុនសិន ពីព្រោះថា ការអនុវត្តការងារពេញលេញគឺនៅតែមានអាទិភាពជាង លើកលែងតែករណីទាំង បី ដែលរៀបរាប់ពីខាងលើក្នុងចំនុចនេះ។

ប្រសិនបើការអនុវត្តការងារពេញលេញនេះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុបើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ ម្ចាស់ការមិនអាចទាមទារចំនួនទឹកប្រាក់ ដែលសមរម្យនឹងសោហ៊ុយដែលចាំបាច់ ក្នុងការជួសជុលវិការៈនោះ ថាជាសំណងនៃការខូចខាតបានទេ[១៣]។

ជាឧទាហរណ៍ ក្នុងករណីធ្វើរថយន្តហើយភ្លេចបាញ់ថ្នាំ គ្រឿងបន្លាស់មួយចំនួនអោយស្អាត ដែលនេះវាគ្រាន់តែជាវិការៈតូចតាចទេ បើសិនជាចង់បាញ់ថ្នាំអោយថ្មីវិញ គឺត្រូវរុះរើរថយន្តទាំងស្រុងផ្នែកខាងមុខ ដែលវាត្រូវការសោហ៊ុយច្រើនហួសហេតុ។ ក្នុងករណីនេះ ម្ចាស់ការពុំអាចទាមទារសោហ៊ុយដើម្បីជួសជុលវិការៈឡើងវិញពីអ្នកម៉ៅការបានឡើយ។

[១៣] មាត្រា ៦៥៩ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

**ច. នៅក្នុងករណីដែលវិការៈកើតឡើងដោយសារសម្ភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ**

នៅស្ថានភាពមួយចំនួន ម្ចាស់ការបានផ្តល់នូវសម្ភារៈ ឬ ការបញ្ជាជាក់លាក់ណាមួយសម្រាប់អោយអ្នកម៉ៅការអនុវត្តតាម។ នៅក្នុងករណីដែល វិការៈកើតឡើងដោយសារសម្ភារៈ ឬ ការបញ្ជាយ៉ាងជាក់លាក់ យ៉ាងច្បាស់លាស់ របស់ម្ចាស់ការ នោះ អ្នកម៉ៅការ មិនចាំបាច់ទទួលខុសត្រូវនឹងវិការៈនោះទេ។ ប៉ុន្តែប្រសិនបើ ម្ចាស់គ្រាន់តែបង្ហាញអំពីបំណងខ្លះៗ ទៅលើអ្នកម៉ៅការ ដូច្នេះបំណងរបស់ម្ចាស់ការ មិនចាត់ទុកជាការបញ្ជាឡើយ។

ប្រសិនបើអ្នកម៉ៅការបានដឹងថា សម្ភារៈ ឬ ការបញ្ជានោះដែលមិនសមស្រប ឬ អាចព្យាករណ៍ទុកថា ការបញ្ជារបស់ម្ចាស់ការ នឹង មានវិការៈកើតឡើង ប៉ុន្តែ អ្នកម៉ៅការ មិនបានផ្តល់ដំណឹងទៅដល់ម្ចាស់ការ នោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវដែលទាក់ទងនឹងវិការៈបានឡើយ។

**១.៥.២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ**

បើរំលឹកពីការបញ្ជាក់ពីខាងលើបន្តិចឃើញថា កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ( មាត្រា ៦៥៣ នៃក្រមដដែល )។ ទន្ទឹមនឹងនេះដែរក្នុងអត្ថន័យមួយទៀតគឺ អ្នកម៉ៅការត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ នៅក្រោយពេលបញ្ចប់ការងារ។

នៅក្នុងករណីនេះ ក៏មានសំនួរចោទឡើងសួរថា តើអ្នកណាដែលត្រូវទទួលបានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការងារនោះ?

ទន្ទឹងនឹងនេះដែរ ដើម្បីឆ្លើយតប ទៅនឹងសំនួរខាងលើ យើងនឹងធ្វើការបែងចែកជាពីរករណីមានដូចជា ករណីកម្មវត្ថុនៃការងារជាអចលនវត្ថុ និង ករណីកម្មវត្ថុនៃការងារជាចលនវត្ថុ។

**ករណីកម្មវត្ថុនៃការងារជាអចលនវត្ថុ** នៅក្នុងករណីដែលកិច្ចសន្យាម៉ៅការ គឺត្រូវសាងសង់អាគារ។ អាគារនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រត្យក្សដាច់ដោយឡែកពីដីបានឡើយ ( មាត្រា ១២២ នៃក្រមដដែល )។ ដូចច្នេះគេសន្មតបានថា ទោះបីជាអ្នកម៉ៅការ បានផ្តល់នូវសម្ភារៈសម្រាប់សាងសង់អាគារក៏ដោយ ក៏កម្មសិទ្ធិនៃអាគារនោះ គឺជារបស់ម្ចាស់ការតាំងពីដើមដំបូងមកម្លេះពោលគឺ កម្មសិទ្ធិនៃអាគារនោះ គឺជាម្ចាស់ដីនៃអាគារនោះតែម្តង។

**ករណីកម្មវត្ថុនៃការងារជាចលនវត្ថុ** នៅក្នុងចំនុចនេះយើងខ្ញុំនឹងធ្វើការបែងចែកនូវគំនិតពិសេស ផ្សេងៗគ្នាចំនួនបីករណីដាច់ដោយឡែកពីគ្នាដែលមានដូចជា៖

គំនិតទី ១ គឺមានន័យថា ម្ចាស់ការត្រូវតែទទួលបាននូវកម្មសិទ្ធិ។ ចំនុចសំខាន់សម្រាប់ករណីនេះគឺថា អ្នកម៉ៅការ គិតថា គាត់បានផលិតនូវទ្រព្យសម្បត្តិរបស់ម្ចាស់ការ និង មិនមែនជាទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គាត់ទេ។ ដោយពិចារណាទៅលើឆន្ទៈរបស់អ្នកម៉ៅការក្នុងចំនុចនេះ គឺកម្មសិទ្ធិត្រូវបានទៅលើម្ចាស់ការ នៅពេលដែលអ្នកម៉ៅការបញ្ចប់នូវការងារនោះ។

គំនិតទី ២ គឺចង់សំដៅថា អ្នកម៉ៅការគឺជាអ្នកទទួលបាននូវកម្មសិទ្ធិ ហើយគាត់ត្រូវផ្ទេរកម្មសិទ្ធិដោយការប្រគល់កម្មវត្ថុនៃការងារទៅអោយម្ចាស់ការ។ គោលគំនិតនៅក្នុងករណីនេះ គឺចង់មានន័យថា គឺចង់ការពារអ្នកម៉ៅការក្នុងករណីដែល ម្ចាស់ការមិនអាចបង់នូវប្រាក់កម្រៃដោយសារក្ស័យធន ឬ ដោយសារករណីផ្សេងៗទៀតផងដែរ។ នៅក្នុងករណីនេះ អ្នកម៉ៅការអាចដកទុកនូវសោហ៊ុយ តាមរយៈការលក់នូវវត្ថុនោះ។

គំនិតទី ៣ គឺមានន័យថា បុគ្គលដែលផ្តល់នូវសម្ភារៈទាំងអស់ ឬ សម្ភារៈចំបង ត្រូវទទួលបាននូវកម្មសិទ្ធិ។ នេះគឺជាយុត្តិសាស្ត្រមួយ សម្រាប់សម្របសម្រួល គំនិតទាំងពីរខាងលើ។ ជាមួយគ្នានេះផងដែរ បើពិចារណាទៅលើមាត្រា ១៩៩ នៃក្រមរដ្ឋប្បវេណីបានចែងថា ប្រសិនបើអ្នកកែច្នៃ បានចូលរួមចំណែកក្នុងការផលិតនូវចលនវត្ថុ ដែលជារបស់អ្នកដទៃ នោះកម្មសិទ្ធិនៅលើវត្ថុនោះ គឺជារបស់នៃម្ចាស់វត្ថុធាតុដើម ប៉ុន្តែប្រសិនបើ តម្លៃដែលបានមកពីការងារនោះ ច្រើនជាងតម្លៃនៃវត្ថុធាតុដើម នោះអ្នកកែច្នៃ ត្រូវទទួលបានកម្មសិទ្ធិលើវត្ថុ ដែលបានកែច្នៃនោះ។

## ១.៦. ការបញ្ចប់កិច្ចសន្យាម៉ៅការ

ចំពោះការបញ្ចប់កិច្ចសន្យាម៉ៅការ នឹងមានការបកស្រាយជាពីរ ចំនុចធំៗ គឺ សិទ្ធិរំលាយរបស់ម្ចាស់ការនៅពេលដែលការងារមិនទាន់បានសម្រេច និង សិទ្ធិរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច។

### ១.៦.១. សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសម្រេច

ម្ចាស់ការអាចរំលាយកិច្ចសន្យានៅពេលណាក៏បាន រហូតដល់ពេលដែលអ្នកម៉ៅការ បានសម្រេចការងារ។ គោលបំណងនៃ ចំនុចនេះគឺ ដើម្បីអោយអ្នកម៉ៅការ និង ម្ចាស់ការ រួចផុតពីកាតព្វកិច្ច ប្រសិនបើម្ចាស់ការមិនចង់បន្តការងារនោះទៀតទេ។ ក៏ប៉ុន្តែ ម្ចាស់ការត្រូវសងសំណងនៃការខូចខាតទៅអោយអ្នកម៉ៅការ ក៏ដូចជាសងនូវសំណងផ្សេងៗ ទៀតដែលជាផលប្រយោជន៍របស់អ្នកម៉ៅការ ( នេះជាស្មារតីនៃមាត្រា ៦៦៣ នៃក្រមដដែល )។

### ១.៦.២. ការរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច

ទាំងភាគី ម្ចាស់ការ ក៏ដូចជាភាគី អ្នកម៉ៅការ អាចរំលាយកិច្ចសន្យា ម៉ៅការបាន ដោយផ្អែកលើបញ្ញត្តិទូទៅ នៃការរំលាយកិច្ចសន្យា ប្រសិនបើភាគីម្ខាងបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ឬ បំពានកាតព្វកិច្ចយ៉ាងធ្ងន់ធ្ងរ។

បញ្ជាក់ ៖ ក្នុងករណីដែលការងារដែលរហ័ស ក្នុងការសម្រេចបានភ្លាមៗ ដូចជា ការកាត់សក់ ការជួសជុល ឬ កិច្ចសន្យាផ្សេងៗទៀត ដែលមានលក្ខណៈបន្ទាន់ គឺមិនអាចរំលាយកិច្ចសន្យាបានទេ ក្រោយពីការសម្រេចការងារនោះ។

## ១.៧. កិច្ចសន្យាម៉ៅការពាណិជ្ជកម្ម

កិច្ចសន្យាម៉ៅការ សំដៅដល់កិច្ចសន្យាដែលក្នុងនោះ អ្នកម៉ៅការជាពាណិជ្ជករចងភ្ជាប់កាតព្វកិច្ចជាមួយនឹងម្ចាស់ការជាពាណិជ្ជករ ឬ មិនមែនជាពាណិជ្ជករក្នុងគោលបំណងអនុវត្តការងារដោយទទួលការទូទាត់ថ្លៃពីម្ចាស់ការ[១៤]។ មានន័យថា កិច្ចសន្យាម៉ៅការបែបពាណិជ្ជកម្មនេះទាមទារអោយអ្នកម៉ៅការដាច់ខាតត្រូវតែជាពាណិជ្ជករ ចំណែកឯ ម្ចាស់ការវិញអាចជាពាណិជ្ជករក៏បាន ឬ មិនមែនជាពាណិជ្ជករក៏បាន ដែលភាគីទាំងពីរបានចងភ្ជាប់នូវកាតព្វកិច្ចជាមួយគ្នា ព្រមទាំងមានការបង់កម្រៃ និង ទូទាត់ថ្លៃពីម្ចាស់ការផងដែរ។

ចំពោះទម្រង់នៃកិច្ចសន្យាម៉ៅការបែបពាណិជ្ជកម្មនេះវិញ គឺមានលក្ខណៈពិសេសនៅត្រង់ថាកិច្ចសន្យាម៉ៅការ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាម៉ៅការបែបពាណិជ្ជកម្មនេះ ដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ មិនអាចតតាំងចំពោះតតិយជនបានឡើយ[១៥]។ ចំពោះកិច្ចសន្យានេះ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ព្រោះថាកិច្ចសន្យានេះមានលក្ខណៈពិសេសមួយដែលមានច្បាប់ពិសេសមួយដែលកំណត់អោយធ្វើជាលាយលក្ខណ៍អក្សរ ដើម្បីអោយមានអានុភាពក្នុងការតតាំងជាមួយតតិយជនណាមួយ។

### ១.៧.១. កាតព្វកិច្ចរបស់អ្នកម៉ៅការ និង កាតព្វកិច្ចរបស់ម្ចាស់ការ

ភាគីនៃកិច្ចសន្យាម៉ៅការ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យស្របតាមកិច្ចសន្យា និង គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់[១៦]។ ដែលមានន័យថា ភាគីម្ចាស់ការ ឬ ភាគីអ្នកម៉ៅការត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួន ឱ្យស្របទៅនឹងលក្ខខណ្ឌដែលមាននៅក្នុងកិច្ចសន្យា ជាពិសេសត្រូវប្រកាន់ភ្ជាប់នូវភាពសុចរិត និង ភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមកជានិច្ច។

មុនពេលអនុវត្តកិច្ចសន្យា អ្នកម៉ៅការត្រូវផ្តល់ឯកសារ និង ព័ត៌មាន ដែលទាក់ទងនឹងការងារ ដើម្បីឱ្យម្ចាស់ការបានដឹងអំពីដំណើរការនៃការអនុវត្តកិច្ចសន្យា។ ឯកសារ និង ពត៌មាននោះ ត្រូវមានលក្ខណៈងាយយល់ និង អាចឱ្យម្ចាស់ការទទួលយកបាន[១៧]។ ជាទូទៅមុនពេលចេញដំណើរក្នុងការអនុវត្តការងារ អ្នកម៉ៅការត្រូវតែមានភាពស្មោះត្រង់មួយក្នុងការ ផ្តល់ឯកសារ ក៏ដូចជាពត៌មានផ្សេងៗ ដែលទាក់ទងនឹងដំណើរការនៃការអនុវត្តកិច្ចសន្យា ឱ្យបានច្បាស់លាស់ និង

[១៤] មាត្រា ១៥៨ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[១៥] មាត្រា ១៦៣ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[១៦] មាត្រា ១៦៧ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[១៧] មាត្រា ១៦៨ កថាខណ្ឌទី ១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

ត្រឹមត្រូវ ហើយការប្រាប់ព័ត៌មានផ្សេងៗនោះត្រូវតែមានលក្ខណៈសាមញ្ញ ហើយងាយយល់ជូនដល់ម្ចាស់ការ ដែលនៅត្រង់ចំនុចនេះគឺចង់ជៀសវាងនូវការយល់ច្រលំ ពីសំណាក់ម្ចាស់ការទៅលើដំណើរការនៃការអនុវត្តកិច្ចសន្យា។

នៅក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា អ្នកម៉ៅការត្រូវមានកាតព្វកិច្ចផ្តល់ឯកសារ និងព័ត៌មានដែលទាក់ទងនឹងការរីកចំរើននៃការងារតាមសំណើរបស់ម្ចាស់ការ[១៨]។ នៅក្នុងកំឡុងពេលដែលអ្នកម៉ៅការ អនុវត្តការងារ នោះអ្នកម៉ៅការត្រូវមានកាតព្វកិច្ច រាយការណ៍នូវព័ត៌មានក៏ដូចជាផ្តល់ឯកសារផ្សេងៗ អំពីដំណើរការនៃការងារនោះតាមសំណើរបស់ម្ចាស់ការ។

នៅពេលដែលអ្នកម៉ៅការអនុវត្តការងារចប់សព្វគ្រប់ អ្នកម៉ៅការត្រូវប្រគល់លទ្ធផលទៅឱ្យម្ចាស់ការដោយយោងតាមខចែងនៅក្នុងកិច្ចសន្យាម៉ៅការ ឬ ដោយមានកំណត់ហេតុស្តីពីការប្រគល់ទទួលច្បាស់លាស់[១៩]។ នេះគឺជាកាតព្វកិច្ចប្រគល់នូវលទ្ធផល ដែលជាកម្មវត្ថុនៃកិច្ចសន្យារបស់អ្នកម៉ៅការទៅលើម្ចាស់ការ ។

ជាមួយគ្នានេះដែរ ម្ចាស់ការត្រូវបង់ថ្លៃឈ្នួលតាមការព្រមព្រៀង និង តាមកាលកំណត់ដូចមានចែងក្នុងកិច្ចសន្យាម៉ៅការទៅឱ្យអ្នកម៉ៅការ។ ប្រសិនបើមិនមានខចែងអំពីកាលកំណត់បង់ថ្លៃឈ្នួលនៅក្នុងកិច្ចសន្យាម៉ៅការទេ នោះម្ចាស់ការត្រូវបង់ថ្លៃឈ្នួលបន្ទាប់ពីការងារត្រូវបានអនុវត្តចប់សព្វគ្រប់[២០]។ ម្ចាស់ការមិនអាចគេចវេសពីការមិនបង់ថ្លៃឈ្នួលបានឡើយ ម្ចាស់ការត្រូវតែបង់ឈ្នួលដែលមានចែងនៅក្នុងកិច្ចសន្យាម៉ៅការ ប៉ុន្តែប្រសិនបើគ្មានការចែងច្បាស់លាស់អំពីការបង់ថ្លៃឈ្នួលនោះទេ នោះម្ចាស់ការត្រូវបង់ថ្លៃឈ្នួលនោះជាបន្ទាន់បន្ទាប់ពីការអនុវត្តការងារចប់សព្វគ្រប់។

នៅក្នុងករណី ដែលម្ចាស់ការបង់ថ្លៃឈ្នួលតាមចំនួនប្រាក់ដែលត្រូវបានកំណត់ក្នុងកិច្ចសន្យាម៉ៅការ ម្ចាស់ការមិនអាចទាមទារឱ្យបញ្ចុះថ្លៃបានឡើយ ហើយអ្នកម៉ៅការមិនអាចទាមទារឱ្យដំឡើងថ្លៃឈ្នួលបានដែរ លើកលែងតែមានខចែងពិសេសនៅក្នុងកិច្ចសន្យាម៉ៅការ[២១]។ នៅពេលដែលបញ្ចប់ការងារហើយ ម្ចាស់ការមិនអាចគេងយកចំណេញដោយ បង្គាប់ឱ្យអ្នកម៉ៅការបន្ថយថ្លៃឈ្នួលបានឡើយ ជាមួយគ្នានេះដែរអ្នកម៉ៅការក៏មិនអាចសុំដំឡើងថ្លៃពីម្ចាស់ការបានឡើយ ប៉ុន្តែបើមានខចែងពិសេសនៅក្នុងកិច្ចសន្យា នោះត្រូវអនុវត្តតាមការកំណត់នៅក្នុងកិច្ចសន្យា។

---

[១៨] មាត្រា ១៦៨ កថាខណ្ឌទី ២ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[១៩] មាត្រា ១៧១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[២០] មាត្រា ១៧២ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[២១] មាត្រា ១៧៤ កថាខណ្ឌទី ១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

### ១.៧.២. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ

ការងារដែលផ្តល់ដោយអ្នកម៉ៅការ ត្រូវតែមានគុណភាពល្អ និង គ្មានវិការៈ។ អ្នកម៉ៅការត្រូវទទួលខុសត្រូវលើការខូចខាត បាត់បង់សម្ភារៈដែលបានទទួលសម្រាប់អនុវត្តការងារ។ អ្នកម៉ៅការត្រូវទទួលខុសត្រូវលើការខូចខាត ឬ បាត់បង់ទំនិញ ឬ ការខូចខាតសំណង់ដែលសាងសង់ ឬ កែលំអដែលបណ្តាលមកពីការងារ។ អ្នកម៉ៅការត្រូវជូនដំណឹងដល់ម្ចាស់ការភ្លាមៗ អំពីការខូចខាត ឬ បាត់បង់ដែលបានកើតឡើង។ អ្នកម៉ៅការត្រូវទទួលខុសត្រូវលើការខូចខាតអាគារ សំណង់បន្ថែម ទំនិញ ឬ សម្ភារៈដែលម្ចាស់ការបានផ្តល់ដល់អ្នកម៉ៅការដើម្បីបំពេញការងារ លើកលែងតែការខូចខាត ឬ វិការៈដែលមានស្រាប់ ចំពោះអាគារ ទំនិញ សំណង់បន្ថែម ឬ សម្ភារៈទាំងនោះ ឬ មានខចែងច្បាស់លាស់ក្នុងកិច្ចសន្យាម៉ៅការ[២២]។ ការសម្រេចការងាររបស់អ្នកម៉ៅការត្រូវតែជាការដែលមានគុណភាពល្អ និង គ្មានវិការៈផងដែរ ប៉ុន្តែប្រសិនបើមានវិការៈដែលបណ្តាលមកពីអនុវត្តការងារ នោះអ្នកម៉ៅការត្រូវតែទទួលខុសត្រូវចំពោះវិការៈនោះ។ ជាមួយគ្នានេះដែរ ប្រសិនបើមានការបាត់បង់កើតមានឡើង នោះអ្នកម៉ៅការត្រូវតែជូនដំណឹងទៅម្ចាស់ការភ្លាមៗ អំពីការខូចខាត ឬ បាត់បង់នោះ។

ជាមួយគ្នានេះផងដែរ អ្នកម៉ៅការត្រូវទទួលខុសត្រូវចំពោះតតិយជនលើការខូចខាត ដែលបណ្តាលមកពីការអនុវត្តការងារ ឬ បណ្តាលមកពីការធ្វេសប្រហែសនៅពេលអនុវត្តការងារ[២៣]។

នៅក្នុងករណីដែលអ្នកម៉ៅការ និង បុគ្គលជំនាញចុះកិច្ចសន្យាម៉ៅការរួមគ្នាជាមួយនឹងម្ចាស់ការ ដើម្បីអនុវត្តការងារ អ្នកម៉ៅការ និង បុគ្គលជំនាញនោះត្រូវទទួលខុសត្រូវរួមគ្នាជាមួយនឹងម្ចាស់ការ។ ប៉ុន្តែ អ្នកម៉ៅការ និង អ្នកជំនាញមិនទទួលខុសត្រូវចំពោះការខូចខាតណាមួយឡើយ ប្រសិនបើមានភស្តុតាងបង្ហាញថា ការខូចខាតបណ្តាលមកពីមកម្ចាស់ការដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តតាមការណែនាំរបស់ខ្លួន ទោះបីអ្នកម៉ៅការបានពន្យល់ម្ចាស់ការពីផលវិបាកផ្នែកបច្ចេកទេសនៃការងារនោះក៏ដោយ[២៤]។ ចំនុចនេះបង្ហាញពីការទទួលខុសត្រូវរួមគ្នា ដោយផ្អែកតាមការចុះកិច្ចសន្យារួមគ្នារបស់អ្នកម៉ៅការ និង អ្នកជំនាញ ជាមួយនឹងម្ចាស់ការ។ ប្រសិនបើមានការខូចខាតកើតឡើងនោះអ្នកម៉ៅការ និង អ្នកជំនាញត្រូវតែទទួលខុសត្រូវរួមគ្នា ព្រោះនេះជាគោលការណ៍សមភាព ក៏ដូចជាការរួមចំណែកនៃការទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើង។

[២២] មាត្រា ១៧៥ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[២៣] មាត្រា ១៧៦ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[២៤] មាត្រា ១៧៨ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

ប៉ុន្តែប្រសិនការខូចខាតកើតឡើងដែលមិនមែនជាកំហុសរបស់អ្នកម៉ៅការ តែកំហុសនោះជារបស់ម្ចាស់ការទៅវិញ នោះអ្នកម៉ៅការ និង អ្នកជំនាញ នឹងរួចផុតពីការទទួលខុសត្រូវចំពោះការខូចខាតនេះ។

**១.៧.៣. ការបញ្ចប់កិច្ចសន្យាម៉ៅការពាណិជ្ជកម្ម**

កិច្ចសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ ដោយការផុតអំឡុងពេលដែលបានកំណត់នោះ។ ប៉ុន្តែប្រសិនបើភាគីបានព្រមព្រៀងគ្នាអនុវត្តកាតព្វកិច្ច ដែលមិនទាន់បានបំពេញចប់សព្វគ្រប់នោះទេ ការបញ្ចប់នោះមិនអាចរំលាយសុពលភាព នៃខចែងក្នុងកិច្ចសន្យាម៉ៅការបានឡើយទោះបីដល់កាលបរិច្ឆេទនៃការបញ្ចប់កិច្ចសន្យាក៏ដោយ[២៥]។ ម្យ៉ាងទៀតកិច្ចសន្យាអាចត្រូវរំលាយផងដែរ ប្រសិនបើភាគីណាមួយមានកំហុសធ្ងន់ធ្ងរ។

[២៥] មាត្រា ១៧៩ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

# ជំពូក២ បញ្ញើ

ចំពោះកិច្ចសន្យាបញ្ញើ ក៏ជាកិច្ចសន្យាពិសេសមួយនៅក្នុងក្រមរដ្ឋប្បវេណីដែរ ដែលនៅខាងក្រោមនេះនឹងមានការបកស្រាយ យ៉ាងច្បាស់លាស់អំពី កិច្ចសន្យាបញ្ញើ។

## ២.១. បទបញ្ញត្តិស្តីពីបញ្ញើ

ចំពោះបទបញ្ញត្តិស្តីពីបញ្ញើ នឹងមានការបកស្រាយទៅលើ និយមន័យ លក្ខណៈរបស់កិច្ចសន្យាបញ្ញើ ករណីយកិច្ចនិងការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ និង ករណីយកិច្ចរបស់អ្នកផ្ញើ។

### ២.១.១. និយមន័យ

បញ្ញើសំដៅទៅលើកិច្ចសន្យាដែលភាគីម្ខាងជាអ្នកទទួលបញ្ញើ សន្យាទទួលយកវត្ថុ បញ្ញើពីភាគីម្ខាងទៀតជាអ្នកផ្ញើ មករក្សាទុកក្នុងអំឡុងពេលដែលបានកំណត់ ហើយនៅក្រោយពេលដែលអំឡុងពេលរក្សាទុកនោះត្រូវបានបញ្ចប់ ត្រូវសងវត្ថុដែលនោះទៅឱ្យអ្នកផ្ញើវិញ។ បើគ្មានកិច្ចសន្យាពិសេសទេ អ្នកផ្ញើពុំមានករណីកិច្ចបង់កម្រៃឱ្យអ្នកទទួលបញ្ញើឡើយ។ ប៉ុន្តែក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើកិច្ចសន្យានោះជាមួយអ្នកផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ឬ ប្រសិនបើមានកំណត់ក្នុងច្បាប់ ទោះបីជាពុំបានធ្វើកិច្ចសន្យាពិសេសចំពោះកម្រៃក៏ដោយ អ្នកទទួលបញ្ញើអាចទាមទារកម្រៃសមរម្យ ពីអ្នកផ្ញើបាន[២៦]។ មានន័យថា បញ្ញើគឺជាកិច្ចសន្យាផ្តល់សេវា ដូចជាកិច្ចសន្យាការងារ អាណត្តិ និងកិច្ចសន្យាម៉ៅការ ប៉ុន្តែសេវាដែលអ្នកទទួលបញ្ញើត្រូវផ្តល់នោះគ្រាន់តែជា **ការរក្សាទុកនូវវត្ថុដែលបានទទួល** តែ ប៉ុណ្ណោះ។ ប្រសិនបើមានការបន្ថែមសេវាផ្សេងទៀត កិច្ចសន្យានេះនឹងអាចក្លាយទៅជាកិច្ចម៉ៅការ។

ឧទាហរណ៍ ៖ កិច្ចសន្យាមួយដែលអ្នកដំណើរបានផ្ញើវត្ថុវ៉ាន់ទៅក្រុមហ៊ុនដឹកជញ្ជូនតាមផ្លូវរថភ្លើងនៅឯស្ថានីយ៍ដែលអ្នកដំណើរត្រូវជិះ ហើយអ្នកដំណើរត្រូវទទួលឥវ៉ាន់នោះវិញនៅស្ថានីយ៍ដែល ខ្លួនទៅដល់ សេវាបែបនេះមិនមែនគ្រាន់តែជាការរក្សាទុកនូវឥវ៉ាន់ប៉ុណ្ណោះទេ ដោយសារតែកាតព្វកិច្ច ដឹកជញ្ជូនឥវ៉ាន់ឱ្យទៅដល់គោលដៅត្រូវបានបន្ថែម ដូច្នេះធាតុផ្សំនៃកិច្ចសន្យាម៉ៅការក៏ត្រូវបានដាក់បញ្ចូលដែរ។

កិច្ចសន្យាស្តុកទំនិញក្នុងឃ្លាំង អ្នកលក់ដុំនៃការជួញដូរទំនិញនៅក្នុងដំណើរការ ចែកចាយទំនិញរវាងផលិតកម្ម និងការលក់ទៅអោយអ្នកប្រើប្រាស់ បានទិញទំនិញពីអ្នកផលិត ហើយ ពួកគេត្រូវរក្សាទំនិញដែលបានទិញហើយនោះ ទុកទម្រាំតែពួកគេលក់ទំនិញទាំងនោះទៅឱ្យអ្នកលក់ដុំ ផ្សេងទៀត ឬអ្នកលក់រាយ។ ក្នុងករណីនេះអ្នកលក់ដុំនេះ និងអ្នកកាន់កាប់ឃ្លាំងបង្កើតនូវកិច្ចសន្យាបញ្ញើ។

[២៦] មាត្រា ៦៦៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ករណីដែលភ្ញៀវបានផ្ញើវត្ថុមានតម្លៃនៅសណ្ឋាគារ ឬអតិថិជនផ្ញើឥវ៉ាន់ជាបណ្ដោះអាសន្ន នៅភោជនីយដ្ឋាន ឬអ្នកដំណើរផ្ញើឥវ៉ាន់ជាបណ្ដោះអាសន្ននៅស្ថានីយ៍ជាដើម។ លើសពីនេះទៀត ករណីបន្ទាប់នេះក៏ជាបញ្ញើដែរ គឺនៅពេលមានវិវាទអំពីកម្មសិទ្ធិលើវត្ថុណាមួយភាគីទាំងសងខាង អាចប្រគល់វត្ថុទៅអោយតតិយជន ធ្វើការថែរក្សានូវវត្ថុនោះ រហូតទាល់តែវិវាទត្រូវបានដោះស្រាយចប់។

**២.១.២. លក្ខណៈរបស់កិច្ចសន្យាបញ្ញើ**

យោងតាមមាត្រា ៦៧០ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាដែលត្រូវបានបង្កើតឡើងដោយការប្រគល់វត្ថុ និងកិច្ចសន្យាឯកតោភាគី ៖ ក្នុងកិច្ច សន្យាបញ្ញើនៅពេលដែលអ្នកទទួលបញ្ញើបានទទួលវត្ថុ ករណីយកិច្ចរបស់អ្នកទទួលបញ្ញើនោះនឹងកើតឡើង មានន័យថាជាគោលការណ៍កិច្ចសន្យាបញ្ញើត្រូវបានបង្កើតឡើងដោយចាំបាច់ត្រូវប្រគល់វត្ថុ។ ការផ្ញើដោយមិនយកកម្រៃគឺជាកិច្ចសន្យាឯកតោភាគី ពីព្រោះអ្នកទទួលបញ្ញើទទួលបន្ទុកនូវករណីយកិច្ចរក្សាទុក និងប្រគល់មកវិញនូវវត្ថុផ្ញើ រីឯអ្នកផ្ញើមិនមានករណីយកិច្ចអ្វីទាំងអស់។

**២.១.២.១. កម្មវត្ថុនៃកិច្ចសន្យាបញ្ញើ**

**(ទីមួយ)** គឺជាវត្ថុ។ ជាធម្មតាកម្មវត្ថុនៃកិច្ចសន្យាបញ្ញើជាចលនវត្ថុ ប៉ុន្តែអចលនវត្ថុក៏អាចក្លាយជាកម្មវត្ថុនៃបញ្ញើដែរ ប៉ុន្តែនៅពេលដែលអចលនវត្ថុត្រូវបានផ្ញើវាមិនគ្រាន់តែ បានគេរក្សាទុកប៉ុណ្ណោះទេ គឺវាត្រូវបានគេប្រគល់ផងដែរ ហេតុដូច្នេះជាទូទៅត្រូវបានគេបកស្រាយថាជាអាណត្តិច្រើនជាងបញ្ញើ ប៉ុន្តែនៅតែអាចមានបញ្ញើអចលនវត្ថុ ប្រសិនបើអចលនវត្ថុគ្រាន់តែបានរក្សាទុកដោយមិនគ្រប់គ្រង។ **(ទីពីរ)** សិទ្ធិលើបំណុលមិនអាចក្លាយជាកម្មវត្ថុនៃបញ្ញើ ប៉ុន្តែប័ណ្ណបំណុល និងលិខិតបញ្ជាក់បំណុល ដែលបញ្ជាក់បង្ហាញសិទ្ធិលើបំណុលអាចក្លាយជាកម្មវត្ថុនៃបញ្ញើដែរ។ **(ទីបី)** ប្រសិនបើប្រាក់ត្រូវបានរក្សាទុកតាមទម្រង់ជាការប្រាក់ក្នុងស្រោមសំបុត្រ ប្រាក់នោះអាចក្លាយជាកម្មវត្ថុ នៃបញ្ញើព្រោះប្រាក់ក្នុងស្រោមសំបុត្រនេះត្រូវបានគេចាត់ទុកដូចគ្នានឹងវត្ថុ ។ ប៉ុន្តែប្រសិនបើប្រាក់មិនត្រូវបានដាក់ក្នុងស្រោមសំបុត្រទេ កិច្ចសន្យានេះមិនមែនបញ្ញើធម្មតាទេ តែជាបញ្ញើបរិភោគ ។

**២.១.២.២. គោលការណ៍មិនយកកម្រៃ**

ក្នុងសង្គមជាក់ស្តែងវត្ថុមួយចំនួនត្រូវបានគេរក្សាទុកដោយមិនយកកម្រៃ ឧទាហរណ៍ដូចជាការថែរក្សាឥវ៉ាន់ឱ្យមានសុវត្ថិភាពនៅសារមន្ទីរ និងការថែរក្សា មានតម្លៃនៅសណ្ឋាគារឱ្យមានសុវត្ថិភាពជាដើម។ ជាគោលការណ៍គឺបញ្ញើមិនយកកម្រៃ ហើយបញ្ញើឱ្យបង់ថ្លៃវិញត្រូវតែមានការសន្យាពិសេស។ ប៉ុន្តែនៅពេលដែលអ្នកទទួលបញ្ញើទទួលការផ្ញើក្នុងនាមជាអាជីវកម្មរបស់ខ្លួន ជាគោលការណ៍បញ្ញើនោះត្រូវតែគិតថ្លៃ។

### ២.១.២.៣. អនុភាពនៃកិច្ចសន្យាបញ្ញើដោយការព្រមព្រៀង

ប្រសិនគ្រាន់តែបានព្រមព្រៀងថានឹងបង្កើតទំនាក់ទំនងបញ្ញើនាពេលអនាគត ភាគីនីមួយៗ អាចដកការព្រមព្រៀងនេះចេញ នៅពេលណាក៏បានរហូតដល់ពេលដែលបានប្រគល់កម្មវត្ថុនៃបញ្ញើនោះ។ ប៉ុន្តែក្នុងករណីដែលបានសន្យាបង្កើតកិច្ចសន្យា បញ្ញើដោយឱ្យបង់ថ្លៃវិញ ប្រសិនបើបានធ្វើឱ្យខូចខាតបង់ដល់ភាគីម្ខាងទៀត ដោយសារកាបដិសេធមិនទទួលវត្ថុបញ្ញើ ផ្ទុយនឹងការសន្យា នោះភាគីដែលជាអ្នកទទួលបញ្ញើមានករណីយកិច្ច ត្រូវសងសំណងនៃ ការខូចខាតនោះ ឱ្យទៅភាគីម្ខាងទៀតប្រសិនបើការបដិសេធនោះគ្មានមូលហេតុត្រឹមត្រូវទេ[២៧]។

នេះមានន័យថាគោលការណ៍នៃបញ្ញើគឺជាការប្រគល់វត្ថុ ប៉ុន្តែត្រង់ចំណុចនេះកិច្ចសន្យាបញ្ញើដោយមានការព្រមព្រៀង ដែលបានបង្កើតឡើង ត្រឹមតាមការព្រមព្រៀងគ្នា ក៏មានអានុភាពដែរ។ តាមជាក់ស្តែង បញ្ញើដោយការព្រមព្រៀងជាការសន្យាជាមុនអំពីបញ្ញើនាពេលអនាគត ហេតុដូច្នេះ វាមិនសមរម្យទេ ក្នុងការផ្តល់ឱ្យមានអានុភាពចងខ្លាំងពេកនោះ ហេតុដូច្នោះ វាស្របទៅនឹងឆន្ទៈរបស់ភាគីទាំងពីរផងដែរ។ ប្រសិនបើកិច្ចសន្យាបញ្ញើដោយការព្រមព្រៀងជាកិច្ចដែលមិនយកកម្រៃ ភាគីទាំងពីរអាចដកការសន្យា នោះពេលណាក៏បាន ។ ឧទាហរណ៍ដោយសារតែ ក នឹងត្រូវទៅបរទេសដើម្បីធ្វើជំនួញនៅខែក្រោយ ក បានជួលផ្ទះឱ្យអ្នកផ្សេង ហើយមិត្តភក្តិរបស់ ក គឺ ខ បានសន្យាថាជាមួយថែរក្សាវត្ថុមានតម្លៃឱ្យ ក ដោយមិនយកកម្រៃ ។ ការសន្យានេះបង្កើតឡើងនូវកិច្ចសន្យាបញ្ញើនាពេលអនាគតរវាង ក និង ខ។ ប្រសិនបើលែងចាំបាច់ត្រូវទៅបរទេសនោះ ក អាចដកការសន្យាវិញ និងមិនធ្វើបញ្ញើនោះបាន។ ម្យ៉ាងទៀតប្រសិនបើ ខ ផ្លាស់ប្តូរចិត្តវិញ ខ អាចបដិសេធមិនរក្សាទុកនូវវត្ថុមានតម្លៃរបស់ ក បាន។ ក្នុងករណីណាមួយក្នុងចំណោមករណីទាំងពីរនេះកើតឡើង ភាគីម្ខាងទៀតនឹងអាចមានបញ្ហា ។ ហេតុដូចនេះក្នុងករណីបញ្ញើដោយមានការព្រមព្រៀងដែលមិនយកកម្រៃ ភាគីអាចដកការព្រមព្រៀងបាន រហូតដល់ពេលមានការប្រគល់វត្ថុដែលជាកម្មវត្ថុនៃបញ្ញើបាន ។

### ២.១.២.៤. កិច្ចសន្យាបញ្ញើដែលបានធ្វើដោយអ្នកគ្មានកម្មសិទ្ធិ

ទោះបីជាអ្នកផ្ញើ គ្មានកម្មសិទ្ធិលើវត្ថុផ្ញើក៏ដោយ ក៏កិច្ចសន្យាបញ្ញើនោះត្រូវបានបង្កើតអនុភាពដែរ។ នៅក្នុងករណីនេះ ទោះបីជាមានពាក្យបណ្តឹង ទាមទារឱ្យសងវត្ថុរបស់កម្មសិទ្ធិករចំពោះអ្នកទទួលបញ្ញើក៏ដោយ ក៏អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះទៅឱ្យអ្នកផ្ញើវិញបានដែរ។ ប៉ុន្តែមិនអាចអនុវត្តបានឡើយក្នុងករណីដែលបណ្តឹងទាមទារឱ្យសង របស់កម្មសិទ្ធិករត្រូវបាន

[២៧] មាត្រា ៦៧១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ទទួលស្គាល់[២៨]។ មានន័យថាដូចគ្នានឹងករណីដែលការលក់ទំនិញនូវវត្ថុរបស់អ្នកដទៃមានអានុភាពកិច្ចសន្យាបញ្ញើនៃវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃក៏មានអានុភាពដែរ។ ប្រសិនបើអ្នកទទួលបញ្ញើប្រគល់នូវវត្ថុបញ្ញើទៅកម្មសិទ្ធិករវិញដោយសារតែកម្មសិទ្ធិករទាមទារឱ្យប្រគល់ វត្ថុបញ្ញើ អ្នកទទួលបញ្ញើអាចនឹងបំពានលើកិច្ចសន្យាដែលបានធ្វើជាមួយអ្នកផ្ញើ។ ម្យ៉ាងវិញទៀតប្រសិនបើអ្នកទទួលបញ្ញើមិនធ្វើតាមការទាមទាររបស់កម្មសិទ្ធិករទេ អ្នកទទួលបញ្ញើនោះនឹងត្រូវទទួល ខុសត្រូវក្នុងការបំពានកម្មសិទ្ធិចំពោះកម្មសិទ្ធិករ។ ដើម្បីដោះស្រាយទ្វេគ្រោះរបស់អ្នកទទួលបញ្ញើ ទោះបីជាកម្មសិទ្ធិករដាក់ពាក្យបណ្ដឹងទាមទារឱ្យសងវត្ថុក៏ដោយ ក៏អ្នកទទួលបញ្ញើមិនមានការទទួលខុសត្រូវចំពោះកម្មសិទ្ធិករ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុនោះឱ្យទៅអ្នកផ្ញើវិញ។ ប៉ុន្តែប្រសិនបើ សេចក្ដីសម្រេចរបស់តុលាការដែលសម្រេចថាអ្នកទាមទារនោះជាកម្មសិទ្ធិបានចូលជាស្ថាពរ អ្នកទទួលបញ្ញើគួរតែសងវត្ថុបញ្ញើទៅកម្មសិទ្ធិករវិញ ហេតុដូចនេះអ្នកទទួលបញ្ញើនឹងត្រូវទទួលខុសត្រូវចំពោះកម្មសិទ្ធិករ ប្រសិនបើអ្នកទទួលបញ្ញើសងវត្ថុបញ្ញើទៅឱ្យអ្នកផ្ញើវិញ ។

### ២.១.៣. ករណីយកិច្ច និងភាពទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ

អ្នកទទួលបញ្ញើមានករណីយកិច្ចមួយចំនួនដូចជា ករណីយកិច្ចរក្សាវត្ថុបញ្ញើ និងរក្សាទុកដោយខ្លួនឯង ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ និងករណីយកិច្ចសងជាដើម។ ថែមពីនេះទៀតអ្នកទទួលបញ្ញើក៏ត្រូវទទួលខុសត្រូវក្នុងករណីដែលបានធ្វើឱ្យបាក់បែក ឬ បាត់បង់។

#### ២.១.៣.១. ករណីយកិច្ចរបស់អ្នកទទួលបញ្ញើ

ករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ អ្នកទទួលបញ្ញើមានករណីយកិច្ចរក្សាទុកវត្ថុបញ្ញើ ដោយព្យាយាមប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយត្រឹមត្រូវ និង សុចរិត។ បើគ្មានការយល់ព្រមពីអ្នកផ្ញើទេ អ្នកទទួលបញ្ញើមិនអាចប្រើបញ្ញើបានឡើយ[២៩]។ និងថែមពីនេះទៀត អ្នកទទួលបញ្ញើមានករណីយកិច្ចរក្សាទុកដោយខ្លួនឯងនូវបញ្ញើ ហើយអ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបានឡើយ។ ក្នុងករណីដែលអ្នកទទួលបញ្ញើអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវ ចំពោះការជ្រើសរើសតាំង និងត្រួតពិនិត្យអ្នកទទួលបញ្ញើដែលត្រូវបានឱ្យរក្សាទុកបន្ត ។

ចំពោះការបកស្រាយនេះ ជាគោលការណ៍អ្នកទទួលបញ្ញើពុំអាចឱ្យតតិយជនរក្សាទុកវត្ថុបញ្ញើបន្តបានឡើយ ហេតុដូចនេះអ្នកទទួលបញ្ញើមានករណីយកិច្ចក្នុងការរក្សាទុកវត្ថុបញ្ញើដោយ

[២៨] មាត្រា ៦៧២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[២៩] យោងតាមមាត្រា ៦៧៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ខ្លួនឯងផ្ទាល់។ ទោះបីជាអ្នកទទួលបញ្ញើគ្រាន់តែប្រតិបត្តិការរក្សាទុកនូវវត្ថុបញ្ញើប៉ុណ្ណោះក៏ដោយ ក៏អ្នកផ្ញើបាន ពិចារណាអំពីជំនាញ និងលក្ខខណ្ឌដទៃផ្សេងទៀតរបស់អ្នកទទួលបញ្ញើនៅពេលសម្រេចផ្ញើវត្ថុនោះដែរ ហេតុដូចនេះវាមិនសមរម្យទេ ដែលអ្នកទទួលបញ្ញើនោះផ្ទុកផ្ដាក់ផ្ញើបន្តនូវវត្ថុបញ្ញើទៅតតិយជនដោយសេរីទេ។ ប៉ុន្តែក្នុងករណីនៃបញ្ញើពាណិជ្ជកម្ម ភាគីនៃកិច្ចសន្យាមានឆន្ទៈអនុញ្ញាតឱ្យមានបញ្ញើបន្ត។ ក្នុងករណីនេះ ប្រការដែលអនុញ្ញាតឱ្យតតិយជន រក្សាទុកបន្តត្រូវតែសរសេរបញ្ចូល ក្នុងកិច្ចសន្យាបញ្ញើ។ ដោយបន្ថែមទៅទៀតវាក្យខណ្ឌទី៣ បានបញ្ជាក់បានច្បាស់លាស់ថា អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវចំពោះការជ្រើសតាំង និងត្រួតពិនិត្យអ្នកទទួលបញ្ញើបន្ត។ ទោះបីជាកិច្ចសន្យាបញ្ញើ អនុញ្ញាតឱ្យមានបញ្ញើក៏ដោយ ក៏អ្នកទទួលបញ្ញើត្រូវតែជ្រើសតាំងនូវអ្នកទទួលបញ្ញើបន្តដែលសមរម្យនៅពេលដែលខ្លួនផ្ញើបញ្ញើបន្តដែរ។ ប្រសិនបើជ្រើសតាំងនូវអ្នកទទួលបញ្ញើបន្តមិនសមរម្យ ហើយវត្ថុ បញ្ញើត្រូវបានខូចខាត ឬបាត់បង់ ដោយសារកំហុសរបស់អ្នកទទួលបញ្ញើបន្ត អ្នកទទួលបញ្ញើជាអ្នកទទួលខុសត្រូវ។ បន្ថែមពីនេះទោះបីជាអ្នកទទួលបញ្ញើបានជ្រើសតាំងអ្នកទទួលបញ្ញើបន្តដែលសមរម្យ ក៏ដោយ ក៏អ្នកទទួលបញ្ញើត្រូវតែទទួលខុសត្រូវចំពោះការត្រួតពិនិត្យមិនបានដិតដល់ដែរ ប្រសិនបើអ្នក ទទួលបញ្ញើយល់ឃើញថាមធ្យោបាយថែរក្សាវត្ថុបញ្ញើរបស់អ្នកទទួលបញ្ញើបន្តនោះ មិនត្រឹមត្រូវ ប៉ុន្តែមិនបានអើពើចំពោះបញ្ញើនេះ ។

**២.១.៣.២. ករណីយកិច្ចជូនដំណឹងរបស់អ្នកទទួលបញ្ញើ**

ប្រសិនបើតតិយជនដែលអះអាងអំពីសិទ្ធិចំពោះ វត្ថុបញ្ញើ បានដាក់ពាក្យបណ្ដឹងចំពោះអ្នកទទួលបញ្ញើ ឬវត្ថុបញ្ញើត្រូវបានរឹបអូស អ្នកទទួលបញ្ញើត្រូវជូន ដំណឹងអំពីហេតុនោះទៅឱ្យអ្នកផ្ញើដោយគ្មានការយឺតយ៉ាវ[៣០] ។ ក្នុងករណីនេះ មានន័យថាអ្នកផ្ញើ មាននូវឱកាសការពារសិទ្ធិរបស់ខ្លួនតាមរយៈការជូនដំណឹងទៅអ្នកផ្ញើនោះក្នុងករណីដែលតតិយជនអនុវត្តសិទ្ធិ ដោយអះអាងថាខ្លួនមានកម្មសិទ្ធិលើវត្ថុបញ្ញើនោះ។ ប្រសិនបើអ្នកផ្ញើទទួលដំណឹងថាតតិយជនបានអនុវត្តសិទ្ធិ អ្នកផ្ញើអាចប្រមូលភស្តុតាងដែលបញ្ជាក់ថាកម្មសិទ្ធិរបស់ខ្លួនមានសុពលភាព ហើយផ្ដល់ភស្តុតាងនោះទៅអ្នកទទួលបញ្ញើ ។

**២.១.៣.៣ ករណីយកិច្ចសងរបស់ អ្នកទទួលបញ្ញើ**

អ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុដដែល ដែលបានទទួលនៅពេលផ្ញើ។ នៅក្នុងករណីដែល អ្នកទទួលបញ្ញើពុំទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬបាក់បែកវត្ថុបញ្ញើទេ

[៣០] យោងតាមមាត្រា ៦៧៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ប្រសិនបើអ្នកទទួលបញ្ញើបានទទួលប្រាក់ធានារ៉ាប់រង ឬវត្ថុផ្សេងទៀតជំនួសវត្ថុបញ្ញើដែលត្រូវបានធ្វើឱ្យ បាត់បង់ ឬ បាក់បែកនោះ អ្នកទទួលបញ្ញើមានករណីយកិច្ចត្រូវសងវត្ថុដែលបានធ្វើឧបាទេសកម្មនោះឱ្យទៅអ្នកផ្ញើវិញ[៣១]។ មានន័យថាប្រសិនបើវត្ថុនោះត្រូវបានធ្វើឱ្យបាត់បង់ ឬ បែកបាក់បណ្តាលមកពីកំហុស របស់អ្នកទទួលបញ្ញើ អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវក្នុងការសងនូវសំណងនៃការខូចខាតទៅឱ្យអ្នក ផ្ញើ។ ប្រសិនបើអ្នកទទួលបញ្ញើគ្មានកំហុសចំពោះការបាត់បង់ ឬការបែកបាក់វត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងទៅវិញនូវវត្ថុតាមភាពជាក់ស្តែង (ប្រសិនបើវត្ថុត្រូវបានធ្វើឱ្យខូចខាតអ្នកទទួលបញ្ញើអាចសងវត្ថុដែលខូចខាតនោះ)។ ប៉ុន្តែប្រសិនបើអ្នកទទួលបញ្ញើបានទទួលនូវវត្ថុជំនួសដែលបាត់បង់ ឬបាក់បែក អ្នកទទួលបញ្ញើត្រូវតែប្រគល់នូវវត្ថុជំនួសនោះទៅឱ្យអ្នកផ្ញើ ។

បើយោងតាមមាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីវិញ ការទាមទារសង ទោះបីជាភាគីបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើក៏ដោយ អ្នកផ្ញើអាចទាមទារឱ្យសងវត្ថុបញ្ញើនោះនៅពេលណាក៏បាន។ ចំពោះករណីសងពីអ្នកទទួលបញ្ញើវិញ ប្រសិន បើភាគីពុំបានកំណត់អំឡុងពេលនៃការសងវត្ថុបញ្ញើទេ អ្នកទទួលបញ្ញើអាចសងវត្ថុបញ្ញើនោះពេលណា ក៏បាន។ ប្រសិនបើមានកំណត់អំឡុងពេលដែលត្រូវសង បើគ្មានមូលហេតុដែលពុំអាចជៀសវាងបានទេ អ្នកទទួលបញ្ញើមិនអាចសងវត្ថុបញ្ញើ នៅមុនពេលកំណត់បានឡើយ នេះបើយោងតាមមាត្រា ៦៨១នៃក្រមរដ្ឋប្បវេណី។

### ២.១.៣.៤. ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ

ក្នុងករណីដែលអ្នកទទួលបញ្ញើបានធ្វើឱ្យបាត់បង់ ឬបានធ្វើឱ្យបែកបាក់វត្ថុបញ្ញើនោះ អ្នកទទួលបញ្ញើត្រូវសងសំណងនៃការខូចខាតនោះ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ បើអ្នកទទួលបញ្ញើបានបញ្ជាក់អំពីការគ្មានកំហុសចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់នោះ។ ក្នុងករណីដែលបញ្ញើត្រូវបានធ្វើ ឡើងតាមការទាមទាររបស់អ្នកទទួលបញ្ញើ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើ មិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់បានឡើយ។ បន្ថែមពីនេះនៅកន្លែងដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងងូតទឹក សិប្បកម្ម/សិល្បៈការផ្សេងទៀតដែលមានភ្ញៀវជួបជុំ ប្រសិនបើកម្មសិទ្ធិករនៃសិល្បៈករទាំងឡាយនោះបានទទួលវត្ថុបញ្ញើពីភ្ញៀវ ប្រសិនបើគ្មានការបញ្ជាក់ថាជាករណីប្រធានសក្តិទេ អ្នកទទួលបញ្ញើមិនអាចរួចផុតពីការទទួលខុសត្រូវចំពោះការធ្វើឱ្យបាត់បង់ ឬបែកបាក់បាន

[៣១] យោងតាមមាត្រា ៦៨២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ឡើយ[៣២]។ មានន័យថាការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើក្នុងការសងសំណងការខូចខាត គឺជាការទទួលខុសត្រូវដោយមានកំហុស។ ក្នុងករណីដែលបញ្ញើមិនត្រូវបានធ្វើឡើងដោយឆន្ទៈដោយសេរីរបស់អ្នកផ្ញើ ប៉ុន្តែទៅតាមការទាមទាររបស់ អ្នកទទួលបញ្ញើ ក្នុងស្ថានភាពជាក់លាក់ណាមួយ។ ឧទាហរណ៍នៅពេលអ្នកណាម្នាក់ចូលទៅក្នុងបណ្ណាល័យ ឬសារមន្ទីរគាត់ត្រូវបានទាមទារឱ្យផ្ញើឥវ៉ាន់ របស់គាត់នៅបណ្ណាល័យ ឬសារមន្ទីរនោះ។ ការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើគឺជាការទទួលខុសត្រូវ ដោយគ្មានកំហុស។ ដូចគ្នាដែរនៅសណ្ឋាគារ ភោជនីយដ្ឋាន និង សិល្បៈការផ្សេងទៀត ដែលមានភ្ញៀវជួបជុំ ត្រូវទទួលខុសត្រូវដោយគ្មានកំហុស អ្នកទទួលបញ្ញើត្រូវទទួលខុសត្រូវដោយគ្មានកំហុសផងដែរ ក្នុងករណីដែលអ្នកផ្ញើវត្ថុដោយស្ម័គ្រចិត្ត ។

បើយោងតាមមាត្រា ៦៧៥ នៃក្រមរដ្ឋប្បវេណី ចំពោះការបន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើដោយមិនយកកម្រៃ នៅក្នុងបញ្ញើដោយមិនយកកម្រៃ តុលាការអាចបន្ថយការទទួលខុសត្រូវសងបំណងនៃការខូចខាតរបស់អ្នកផ្ញើរ ដោយពិចារណាទៅលើស្ថានភាពនៃទ្រព្យសម្បត្តិភាគីទាំងសងខាង និងកាលៈទេសៈផ្សេងៗទៀតបាន។ បន្ថែមពីនេះត្រង់ចំនុចមួយវិញទៀតការសម្រាលការទទួលខុសត្រូវក្នុងករណី ដែលមិនបានរាយការណ៍អំពីវត្ថុដែលមានតម្លៃខ្ពស់ នៅក្នុងករណីដែលអ្នកផ្ញើបានផ្ញើប្រាក់ ឧបករណ៍អាចជួញដូរបាន និងវត្ថុដែលមានតម្លៃខ្ពស់ផ្សេងទៀត បើយោងតាមមាត្រា ៦៧៦ នៃក្រមរដ្ឋប្បវេណី ប្រសិនបើអ្នកផ្ញើមិនបានរាយការណ៍អំពីប្រភេទ និងតម្លៃនោះទៅឱ្យអ្នកទទួលបញ្ញើទេ តុលាការបន្ថយការទទួលខុសត្រូវសងសំណងនៃការខូចខាតរបស់អ្នកទទួលបញ្ញើបាន។ មានន័យថា ត្រង់ចំណុចនេះមានការកាត់បន្ថយការទទួលខុសត្រូវរបស់អ្នកទទួលបញ្ញើ ក្នុងករណីដែលអ្នកផ្ញើខកខានមិនបានរាយការណ៍ ទៅអ្នកទទួលបញ្ញើថាវត្ថុផ្ញើជាវត្ថុមានតម្លៃ។ ប្រសិនបើវត្ថុបញ្ញើជាវត្ថុមានតម្លៃ អ្នកទទួលបញ្ញើនឹងធ្វើការរក្សាទុកដោយប្រុងប្រយ័ត្ន ពិសេសដើម្បីកុំឱ្យមានការខូចខាត។ ផ្ទុយទៅវិញប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថាវត្ថុបញ្ញើនោះ ជាវត្ថុដែលមានតម្លៃទេ អ្នកទទួលបញ្ញើនឹងធ្វើការប្រុងប្រយ័ត្នធម្មតាតែប៉ុណ្ណោះ។ លើសពីនេះទៅទៀតដោយសារតែការរក្សាទុកនូវដែលមានតម្លៃ ទាមទារឱ្យមានការចំណាយច្រើនសន្ធឹកសន្ធាប់ដែរនោះ អ្នកទទួលបញ្ញើ ទាមទារកម្រៃសម្រាប់ការរក្សាទុកនោះលើសពីធម្មតា។ ប៉ុន្តែ ប្រសិនបើអ្នកទទួលបញ្ញើមិនបានដឹងថាវត្ថុនោះមានតម្លៃខ្ពស់ អ្នកទទួលបញ្ញើមិនអាចធ្វើដូច្នោះបានឡើយ។ ដោយមូលហេតុនេះគោលគំនិតត្រង់ចំណុចនេះគឺឱ្យអ្នកផ្ញើរាយការណ៍ប្រាប់

[៣២] មាត្រា ៦៧៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

អ្នកទទួលបញ្ញើថាវត្ថុនោះមានតម្លៃ។ ករណីដែលមាន ការចាត់ចែងផល ក្នុងពេលដែលបានទទួលផល ឬចំណូលដែលកើតឡើងពីវត្ថុបញ្ញើ អ្នកទទួលបញ្ញើត្រូវប្រគល់ផល ឬចំណូលនោះឱ្យទៅអ្នកផ្ញើ។ ជាឧទាហរណ៍មួយចំនួននៃផល ដូចជាកូនសត្វដែលកើតមកពីសត្វដែលត្រូវបានផ្ញើ និងផលចំណេញដែលបានមកពីអចលនវត្ថុ ដែលត្រូវបានផ្ញើ ( ដូចជាផលចំណេញបានមកពីកន្លែងចតរថយន្តដែលបានដាក់បញ្ញើ ) យោងតាមមាត្រា ៦៨៣នៃក្រមរដ្ឋប្បវេណី។

### ២.១.៤. ករណីយកិច្ចរបស់អ្នកផ្ញើ

អ្នកផ្ញើចាំបាច់ត្រូវបង់សោហ៊ុយដែលចាំបាច់ក្នុងការរក្សាទុកវត្ថុបញ្ញើ អ្នកទទួលបញ្ញើអាចទាមទារសំណង នៃការខូចខាត ដែលបណ្តាលមកពី វត្ថុបញ្ញើដោយមិនមែនជាកំហុសរបស់ខ្លួនពីអ្នកផ្ញើបាន[៣៣]។ ក្នុងន័យនេះអ្នកផ្ញើមានករណីយកិច្ចពីរជាកំណត់ ដូចជា៖

- សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើ និងបន្ទុកនៃការខូចខាតដែលបណ្តាលមកពីបញ្ញើ សូម្បីតែក្នុងករណីនៃបញ្ញើដោយមិនយកកម្រៃ សោហ៊ុយសម្រាប់ការរក្សាទុកវត្ថុបញ្ញើក៏ត្រូវតែជាបន្ទុករបស់អ្នកផ្ញើរដែរ។ ពីព្រោះមិនយកកម្រៃ មានន័យថាមិនបង់លាភសក្ការៈទៅអ្នកទទួលបញ្ញើ ដូច្នេះកម្រៃ មិនពាក់ព័ន្ធជាមួយសោហ៊ុយ ចំណាយជាក់ស្តែងសម្រាប់ការរក្សាទុកទេ។ ប្រសិនបើអ្នកទទួលបញ្ញើរក្សាទុកវត្ថុដោយភាពក្លាសេនោះ អ្នកទទួលបញ្ញើអាចទាមទារថ្លៃអគ្គិសនីជាអាទិ៍ ពីអ្នកផ្ញើបាន សូម្បីតែក្នុងករណីជាបញ្ញើដោយមិនយកកម្រៃក៏ដោយ។ ប្រសិនបើអ្នកទទួលបញ្ញើទទួលការខូចខាតដោយសារវត្ថុបញ្ញើ ដោយមិនមែនមកពីកំហុសរបស់អ្នកទទួលបញ្ញើ វាជាការសមស្របនឹងសមភាព ដែលអ្នកផ្ញើត្រូវសងសំណងការខូចខាតនោះ ទៅអ្នកទទួលបញ្ញើ។ ឧទាហរណ៍ ប្រសិនបើផ្ទះរបស់អ្នកទទួលបញ្ញើត្រូវបានបំផ្លិចបំផ្លាញ ដោយសារតែការផ្ទុះវត្ថុបញ្ញើ អ្នកផ្ញើត្រូវទទួលបន្ទុកនូវការខូចខាតនោះ។ អ្នកផ្ញើត្រូវបង់សោហ៊ុយ ឬសងសំណងនៃការខូចខាតនៅពេលដែលសោយហ៊ុយ ឬការខូចខាតនោះកើតឡើង។ ម្យ៉ាវិញទៀត យោងតាមមាត្រា៦៨៨ នៃក្រមរដ្ឋប្បវេណី បានលើកឡើងពី សិទ្ធិឃាត់ទុករបស់អ្នកទទួលបញ្ញើករណី អ្នកទទួលបញ្ញើអាចឃាត់ទុកវត្ថុបញ្ញើរហូតដល់ពេលដែលអ្នកផ្ញើបានបង់សោហ៊ុយ និងសងសំណងនៃការខូចខាត។

## ២.២. បញ្ញើដោយរួមបញ្ចូលគ្នា និងបញ្ញើបរិភោគ

ចំពោះបញ្ញើរួមបញ្ចូលគ្នា និង បញ្ញើបរិភោគ នឹងមានការបកស្រាយ អំពីលក្ខណៈរវាងបញ្ញើទាំងពីរនេះ ដាច់ដោយឡែកពីគ្នាដូចខាងក្រោម ៖

[៣៣] មាត្រា ៦៨៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.២.១. បញ្ញើដោយរួមបញ្ចូលគ្នា

ប្រសិនបើអ្នកទទួលបញ្ញើទទួលបញ្ញើនូវវត្ថុ ដែលមានប្រភេទដូចគ្នាពីអ្នកផ្ញើច្រើននាក់ ហើយអាចរក្សាទុករួមបញ្ចូលគ្នា ដោយមិនចាំបាច់បែងចែកវត្ថុបញ្ញើនោះ តាមកិច្ចសន្យាអ្នកផ្ញើនីមួយៗ មានសិទ្ធិទៅតាមសមាមាត្រនៃចំនួនវត្ថុផ្ញើរបស់ខ្លួន ចំពោះវត្ថុទាំងមូលដែលត្រូវបានរក្សាទុកដោយរួមបញ្ចូលគ្នា[៣៤] ។

ឧទាហរណ៍ ក្នុងករណីដែលម្ចាស់ឃ្លាំងត្រូវបានកសិករជាច្រើន ផ្ទុកផ្ដាក់ឱ្យរក្សាទុកស្រូវរបស់ពួកគេម្នាក់ៗ ១០ តោនជាអាទិ៍។ ប្រសិនបើស្រូវនោះមានប្រភេទ និងគុណភាពដូចគ្នា ការរក្សាទុកដោយរួមគ្នាគឺមានលក្ខណៈសន្សំសំចៃ និងងាយគ្រប់គ្រង។ ប្រសិនបើស្រូវរបស់កសិករច្រើននាក់ត្រូវបានរក្សាទុករួមគ្នា ស្រូវនោះត្រូវលាយចូលគ្នា ហេតុដូច្នេះស្រូវដែលម្ចាស់ឃ្លាំងនឹងសងគេជាស្រូវ ដែលត្រូវបានលាយចូលគ្នានោះ ពោលគឺមិនមែនជាស្រូវដើមដែលដាក់ជាបញ្ញើនោះទេ បើនិយាយឱ្យតឹងរ៉ឹង។

### ២.២.២. បញ្ញើបរិភោគ

នៅក្នុងកិច្ចសន្យាបញ្ញើ បើបានព្រមព្រៀងឱ្យអ្នកទទួលបញ្ញើអាចបរិភោគវត្ថុបញ្ញើបាន អ្នកទទួលបញ្ញើមានករណីយកិច្ចសងវត្ថុដែលមានប្រភេទ និងចំនួនដូចគ្នា និងវត្ថុបញ្ញើនោះ[៣៥]។ ក្នុងបញ្ញើធម្មតា អ្នកទទួលបញ្ញើរក្សាទុកវត្ថុដែលខ្លួនបានទទួលពីអ្នកផ្ញើហើយសងវិញនូវវត្ថុដដែល ដែលពេលកំណត់សង រីឯក្នុងករណីនៃបញ្ញើបរិភោគអ្នកទទួលបញ្ញើអាចបរិភោគវត្ថុដែលត្រូវបានផ្ញើដោយអ្នកផ្ញើនោះ ហើយនៅពេលកំណត់សង អ្នកទទួលបញ្ញើអាចយកវត្ថុដែលមានប្រភេទដូចគ្នាមកសងវិញបាន ។ ក្នុងករណីនៃបញ្ញើបរិភោគវាត្រូវបានគិតថា កម្មសិទ្ធិនៃវត្ថុបញ្ញើត្រូវបានផ្ទេរទៅអោយអ្នកទទួលបញ្ញើ។ បញ្ញើបរិភោគអាចអនុវត្តបានចំពោះប្រាក់ ផលិតផលកសិកម្ម និងគ្រឿងស្រវឹង។ បញ្ញើនៅធនាគារ ត្រូវបានគិតថា ជាបញ្ញើបរិភោគ។

## ២.៣. វិសុណ្ឋាប័ន

វិសុណ្ឋាប័ន គឺជាកិច្ចសន្យាពិសេសមួយដែលរួមផ្សំជាមួយនឹងកិច្ចសន្យាបញ្ញើ ដែលនឹងមានការបកស្រាយ អំពី និយមន័យ ដែលរួមផ្សំជាមួយនឹងលក្ខខណ្ឌសុពលភាព លើសពីនេះទៅទៀតនឹងនិយាយអំពីភាគីនៃវិសុណ្ឋាប័ន ព្រមទាំងការ រំលាយវិសុណ្ឋាប័នជាដើម។ ចំពោះប្លង់ដែលបានរៀបរាប់ខាងលើនេះនឹងមានការបកស្រាយយ៉ាងច្បាស់លាស់នៅខាងក្រោមនេះ ៖

---

[៣៤] មាត្រា ៦៨៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៣៥] មាត្រា ៦៩០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ២.៣.១. និយមន័យ

វិសុណ្ឋាប័នសំដៅទៅលើកិច្ចសន្យាមួយពេលដែលបុគ្គលច្រើននាក់ មានវិវាទលើសិទ្ធិកាន់កាប់ ឬកម្មសិទ្ធិនៃវត្ថុហើយបានយកវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ទៅផ្ញើទុកនៅតតិយជនដែលគេបានកំណត់ហៅថា វិសុណ្ឋាបនិក រួចមកតតិយជននោះត្រូវរក្សាទុកនូវវត្ថុនៃវិវាទរហូតដល់ពេលអ្នកដែលមានសិទ្ធិលើវត្ថុនោះ ត្រូវបានកំណត់ជាស្ថាពរ[៣៦]។

ម្យ៉ាងវិញទៀត វិសុណ្ឋាប័នមានតួនាទីស្រដៀងគ្នាទៅនឹងការតម្កល់ ប៉ុន្តែវិសុណ្ឋាប័នមានភាពខុសគ្នាពីការតម្កល់ត្រង់ចំណុចមួយចំនួនដូចតទៅះ

-ទីមួយគឺចំពោះការតម្កល់ គឺការិយាល័យតម្កល់ទទួលរក្សាទុកនូវ វត្ថុនៃវិវាទក្នុងនាមជាស្ថាប័នសាធារណៈ រីឯចំពោះវិសុណ្ឋាប័នវិញអ្នកដែលរក្សាទុកវត្ថុនោះមិនចាំបាច់ជាស្ថាប័នសាធារណៈឡើយ ។

-ទីពីរគឺជាធម្មតាការតម្កល់គ្របដណ្តប់តែលើប្រាក់ និងឧបករណ៍ដែលអាចជួញដូរបានប៉ុណ្ណោះ ចំណែកឯវិសុណ្ឋាប័នវិញគ្របដណ្តប់លើចលនវត្ថុ និងអចលនវត្ថុ ។

### ២.៣.២. លក្ខខណ្ឌនៃសុពលភាព

បើគ្មានការយល់ព្រមពីបុគ្គលដែលអះអាងអំពីសិទ្ធិទាំងអស់គ្នាទេ បញ្ញើនៃវត្ថុដែលជាកម្មវត្ថុវិវាទពុំមានសុពលភាពឡើយ[៣៧]។ ក៏ប៉ុន្តែអាចមាន វិសុណ្ឋាប័នដោយការបង្គាប់របស់តុលាការក្នុងករណីដែលសិទ្ធិកាន់កាប់វត្ថុ ឬ កម្មសិទ្ធិនៃវត្ថុត្រូវបានយកជាកម្មវត្ថុ នៃវិវាទនៅក្នុងតុលាការ ទោះបីជាគ្មានការព្រមព្រៀងរវាង ភាគីក៏ដោយ តុលាការអាចឱ្យតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទបាន។

### ២.៣.៣. ភាគីនៃវិសុណ្ឋាប័ន

ក្នុងករណីដែលបុគ្គលច្រើននាក់អះអាងអំពីសិទ្ធរបស់ខ្លួន ចំពោះវត្ថុដែលកាន់កាប់ដោយបុគ្គលដទៃ បុគ្គលដែលមានវិវាទច្រើននាក់នេះអាចធ្វើកិច្ចសន្យាត្រូវអោយតតិយជនរក្សាទុកវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយទទួលការយល់ព្រមពីអ្នកកាន់កាប់ ។ ក្នុងករណីនេះ កិច្ចសន្យាវិសុ-ណ្ឋាប័ន ត្រូវមានអានុភាពនៅពេលដែលអ្នកកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ បានប្រគល់វត្ថុនោះទៅឱ្យតតិយជន[៣៨]។

---

[៣៦] មាត្រា ៦៩២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៣៧] មាត្រា ៦៩៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៣៨] មាត្រា ៦៩៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ឧទាហរណ៍ នៅពេលដែល ភាគី ក បានកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការលក់ដែលមាន លោក ខ និង លោក គ អះអាងខ្លួនជាអ្នកទិញ និង ខ និង គ បានទាមទារឱ្យ ភាគី ក ប្រគល់វត្ថុនោះ ដូចនេះ ក បានផ្ញើវត្ថុនោះទៅ តតិយជនដើម្បីជៀសវាងការពាក់ព័ន្ធក្នុងវិវាទរវាង ខ និង គ ។ វិសុណ្ឋាប័ននឹងមានអានុភាពលុះត្រា តែ ក ប្រគល់វត្ថុទៅតតិយជនដោយមានការយល់ព្រម ។

ចំនែកក្នុងមាត្រា ៦៩៥ នៃក្រមរដ្ឋប្បវេណី បានបង្ហាញពីគោលការណ៍យកកម្រៃ នៅក្នុងវិសុណ្ឋាប័នអ្នកផ្ញើមានករណីយកិច្ចត្រូវបង់កម្រៃឱ្យទៅ វិសុណ្ឋាបនិក ។ ក្នុងករណីដែលភាគីមិនបានកំណត់អំពីចំនួនទឹកប្រាក់នៃកម្រៃទេ វិសុណ្ឋាបនិកអាចទាមទារចំនួនទឹកប្រាក់ជាកម្រៃដែលសមរម្យពីអ្នកផ្ញើបាន ។

មានន័យថា វិសុណ្ឋាប័នអនុវត្តនូវតួនាទីពិសេសដើម្បីរក្សាទុកវត្ថុដើម្បីដោះស្រាយវិវាទ ជាជាងរក្សាទុកវត្ថុនោះដោយសារតែសន្តានចិត្ត។ ដូច្នេះវិសុណ្ឋាបនិកត្រូវយកចិត្តទុកដាក់ដោយប្រុង-ប្រយ័ត្នក្នុងការរក្សាទុក និងប្រគល់វត្ថុបញ្ញើនោះ ហើយវាមិនសមរម្យទេ បើយកការផ្ញើដោយមិនយកកម្រៃមកធ្វើជាគោលការណ៍។ បន្ថែមលើនេះទៀត ប្រសិនបើវិសុណ្ឋាប័នមិនយកកម្រៃទេ គ្មាននរណាព្រមទទួលនូវបញ្ញើនេះទេ។ ការកើតឡើងនូវវិវាទមិនអាចព្យាករណ៍បានទេ ហើយដើម្បីអាចធ្វើវិសុណ្ឋាប័នឱ្យបានទាន់ពេលវេលា នៅពេលដែលវិវាទកើតឡើងចាំបាច់មានបុគ្គលដែលអាចទទួលតួនាទីជាវិសុណ្ឋាប័នជាទៀងទាត់។ ប្រសិនបើវិសុណ្ឋាប័ន ជាវិសុណ្ឋាប័នដែលមិនយកកម្រៃ វិសុណ្ឋានិកនឹងមិនកើនចំនួនទេ នេះជាហេតុផលដែលយកវិសុណ្ឋាប័នយកកម្រៃធ្វើជាគោលការណ៍ ។

យោងតាមមាត្រា ៦៩៦ នៃក្រមរដ្ឋប្បវេណី បានបញ្ជាក់ ពីការសងវត្ថុដែលជាកម្មវត្ថុនៃវិវាទ វិសុណ្ឋាបនិកមានករណីយកិច្ចត្រូវសងវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ ចំពោះបុគ្គលដែលត្រូវបានទទួលស្គាល់ថា មានសិទ្ធិនៅក្រោយពេលដែលវិវាទបានបញ្ចប់។

### ២.៣.៤. ការរំលាយកិច្ចសន្យាវិសុណ្ឋាប័ន

វិសុណ្ឋាបនិកពុំអាចសងវត្ថុនោះ ទៅឱ្យអ្នកផ្ញើនៅមុនពេលវិវាទនោះត្រូវបានដោះស្រាយឡើយ លើកលែងតែករណីមានការយល់ព្រមពីអ្នកផ្ញើទាំងអស់[៣៩]។ មានន័យថា នៅពេលអ្នកផ្ញើខ្លះក្នុងចំណោមអ្នកផ្ញើវត្ថុដែលជាកម្មវត្ថុនៃវិវាទទាមទារឱ្យសងវត្ថុ វិសុណ្ឋាបនិកមិនអាចសងទៅឱ្យអ្នកផ្ញើនោះបានឡើយ។ ប៉ុន្តែប្រសិនបើអ្នកផ្ញើទាំងអស់យល់ព្រមវិសុណ្ឋាបនិកត្រូវ សងវត្ថុនោះ។

[៣៩] មាត្រា ៦៩៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

# ជំពូក៣ អាណត្តិ

កិច្ចសន្យាអាណត្តិ ក៏វាមិនខុសពីកិច្ចសន្យាមុនៗដែរ គឺជាកិច្ចសន្យាពិសេសមួយដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណី។

## ៣.១. និយមន័យ និង លក្ខណៈទូទៅ

អាណត្តិ សំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងហៅថាអាណត្តិទាយក ប្រគល់សិទ្ធិអំណាចអោយភាគីម្ខាងទៀតហៅថាអាណត្តិគាហកធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយ[៤០]។

ទន្ទឹមនឹងនេះដែរ ក៏មានសំនួរមួយចោទឡើងថា តើពាក្យថា កិច្ចការ នៅក្នុងកិច្ចសន្យាអាណត្តិមានន័យយ៉ាងដូចម្តេចដែរ?

ពាក្យថា កិច្ចការ នៅក្នុងកិច្ចសន្យា អាណត្តិ រាប់បញ្ចូលរាល់កិច្ចការដូចជា ៖ ការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិក្នុងការធ្វើបណ្តឹងជាដើម។

ជាឧទាហរណ៍ ( សិទ្ធិក្នុងការធ្វើបណ្តឹង ) អាណត្តិទាយក បានផ្តល់សិទ្ធិអំណាចក្នុងការធ្វើបណ្តឹងទៅអោយ អាណត្តិគាហក ដែលជាមេធាវី ជាដើម។ នេះក៏ជាកិច្ចសន្យាអាណត្តិដែរ។

នៅក្នុងករណីពិសេសមួយទៀត ទំនាក់ទំនងរវាងគ្រូពេទ្យ និង អ្នកជំងឺ ក៏ចាត់ទុកជាអាណត្តិដែរ។ ប៉ុន្តែ ការរក្សាទុកវត្ថុ មិនរាប់បញ្ចូលទៅក្នុងកិច្ចការ នៅក្នុងអាណត្តិទេ គឺស្ថិតនៅក្នុងកិច្ចសន្យាបញ្ញើ។

ជាមួយគ្នានេះផងដែរ អាណត្តិ និង កិច្ចសន្យា បញ្ញើ ក៏មានទំនាក់ទំនងគ្នា យ៉ាងពិសេសផងដែរ។ អាណត្តិ និង បញ្ញើ គឺជាកិច្ចសន្យាដែលផ្តល់នូវសេវាកម្មដូចគ្នា ប៉ុន្តែ កិច្ចសន្យាទាំងពីនេះខុសគ្នានៅត្រង់ថា ៖ ចំពោះកិច្ចសន្យាបញ្ញើ គឺ អ្នកទទួលបញ្ញើត្រូវផ្តល់នោះគឺ ការរក្សាទុកវត្ថុដែល **បានទទួល** តែប៉ុណ្ណោះ។ ចំណែក ឯសេវា ដែល ត្រូវផ្តល់នៅក្នុងកិច្ចការអាណត្តិ គឺចាត់ចែងរាល់គ្រប់កិច្ចការ ដូចជាការធ្វើកិច្ចសន្យា អន្តរការីនៃអចលនវត្ថុ សិទ្ធិអំណាចក្នុងការធ្វើបណ្តឹងជាដើម។ នៅក្នុងអត្ថន័យដែលបានរៀបរាប់ខាងលើនេះ គេអាចនិយាយបានថា បញ្ញើគឺជាប្រភេទមួយនៃកិច្ចសន្យាអាណត្តិ ប៉ុន្តែវាត្រូវបានបញ្ញត្តិដោយឡែក នៅក្នុងក្រមរដ្ឋប្បវេណី។

ជាមួយគ្នានេះផងដែរ មានចម្ងល់មួយបានចោទឡើងថា តើអាណត្តិ ប្រកាន់នូវគោលការណ៍យកកម្រៃ ឬ មិនយកកម្រៃ ឬ ទាំងពីរ?

អាណត្តិអាចធ្វើដោយយកកម្រៃ ឬ មិនយកកម្រៃបាន។ បើពុំបានបង្ហាញឆន្ទៈ អំពីការធ្វើដោយយកកម្រៃទេ ត្រូវសន្មតថាជាអាណត្តិដោយមិនយកកម្រៃ[៤១]។ ក្នុងន័យនេះ អាណត្តិគឺជាកិច្ច

---

[៤០] មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៤១] មាត្រា ៦៣៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សន្យាដែលយកតំលៃថ្នូរ ឬ ជាកិច្ចសន្យាមិនយកតំលៃថ្នូរ ដែលអត្ថន័យនេះមានន័យថា អាណត្តិគឺជាកិច្ចសន្យាមិនយកតំលៃថ្នូរទេប្រសិនបើ ភាគីមិនបានបង្កើតការព្រមព្រៀង ដែលទាក់ទងទៅនឹងការយកតំលៃថ្នូរនោះ។ ចំពោះការបង្ហាញឆន្ទៈនៃការព្រមព្រៀង អាចលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ក៏បាន នៅពេលបង្កើតកិច្ចសន្យា។

## ៣.២. លក្ខខណ្ឌ

អាណត្តិ គឺជាកិច្ចសន្យាមួយដែលវាមានលក្ខណៈងាយស្រួល ដែលលក្ខខណ្ឌរបស់អាណត្តិ គឺ គ្រាន់តែមានការព្រមព្រៀងជាការស្រេច ដែលមានន័យថា មិនចាំបាច់តម្រូវឱ្យធ្វើជាលាយ លក្ខ-ណ៍អក្សរនោះទេ។ នៅក្នុងចំនុចនេះគឺមានន័យថា អោយតែមានឆន្ទៈត្រូវគ្នារវាងភាគីទាំងសងខាង នោះអាណត្តិ នឹង ត្រូវបានបង្កើតឡើង។ ម៉្យាងទៀត នៅក្នុងករណីដដែល គ្រាន់តែអាណត្តិទាយក ប្រគល់សិទ្ធិអំណាចអោយអាណត្តិគាហក ធ្វើកិច្ចការណាមួយ ហើយអាណត្តិគាហកឯកភាពទទួល ធ្វើកិច្ចនោះ វាជាការស្រេច។

ជាឧទាហរណ៍ បុគ្គល **ក** មានបំណងចង់ទិញឡានមួយគ្រឿង តែដោយសារតែ គ្មានពេលវេលាទៅទិញ ឬ ចង់អោយបុគ្គល **ខ** ទៅទិញជំនួស ព្រោះថា បុគ្គល **ខ** គាត់មានជំនាញមើលឃើញថាឡាននោះល្អ ឬ មិនល្អ។ ដូច្នេះ បុគ្គល **ក** បានស្នើរអោយបុគ្គល **ខ** ទៅទិញឡានជំនួស។ បុគ្គល**ខ** ក៏យល់ព្រមតាមសំណើរ របស់បុគ្គល **ក**។ ដូច្នេះ ក្នុងករណីនេះ កិច្ចសន្យា អាណត្តិត្រូវបានបង្កើតឡើង។

## ៣.៣. ទំនាក់ទំនងរវាង អាណត្តិ និង ការតំណាង

អាណត្តិ និង ការតំណាងពិតជាមាន ភាពស្រដៀងគ្នា និង ភាពខុសគ្នាមួយចំនួនគួរអោយកត់សំគាល់។

អាណត្តិ គឺសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថា អាណត្តិទាយក ប្រគល់សិទ្ធិអំណាចអោយភាគីម្ខាងទៀត ហៅថា អាណត្តិគាហក ធ្វើការចាត់ចែងកិច្ចការដើម្បីអាណត្តិទាយក[៤២] ផ្ទុយទៅវិញ ការតំណាងសំដៅទៅលើទំនាក់ទំនងគតិយុត្តដែលអានុភាពនៃកិច្ចសន្យា ត្រូវមានចំពោះម្ចាស់សិទ្ធិផ្ទាល់ ក្នុងករណីដែលអ្នកតំណាង ធ្វើកិច្ចសន្យាជាមួយភាគីម្ខាងទៀត ដោយបង្ហាញថា ការធ្វើកិច្ចសន្យានោះគឺធ្វើសម្រាប់ម្ចាស់សិទ្ធិក្នុងទំហំនៃសិទ្ធិតំណាង [៤៣]។ ភាពខុសគ្នារវាងអាណត្តិ និង ការតំណាង មាននៅត្រង់ចំនុចមួយចំនួនដូចខាងក្រោម ៖

[៤២] មាត្រា ៦៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៤៣] មាត្រា ៣៦៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ឧបមាថា ៖ **ក** បានអោយ **ខ** ទៅទិញរថយន្តពី **គ**។ ដូច្នេះ ការបែងចែកដូចជា

-ចំពោះអាណត្តិ ៖ ក(អាណត្តិទាយក) ខ(អាណត្តិគាហក) និង គ(ភាគីម្ខាងទៀត)។

-ចំពោះការតំណាង ៖ ក(ម្ចាស់សិទ្ធិ) ខ(អ្នកតំណាង) និង គ(ភាគីម្ខាងទៀត)។

នៅក្នុងករណីដដែលយើង នឹងធ្វើការបែងចែក ភាពខុសគ្នា រវាង អាណត្តិ និង ការតំណាង ជាបីចំនុចធំៗ ដូចខាងក្រោម ៖

(ទីមួយ) ចំពោះអាណត្តិ អាណត្តិគាហក បានទៅចុះកិច្ចសន្យាទិញរថយន្តជាមួយភាគីផ្សេងទៀត នោះ អាណត្តិគាហកពុំចាំបាច់ប្រាប់ភាគីអ្នកលក់ ថាខ្លួនធ្វើសម្រាប់អាណត្តិទាយកឡើយ។ ប៉ុន្តែ ចំពោះការតំណាងវិញ អ្នកតំណាងត្រូវតែប្រាប់ភាគីអ្នកលក់ថា ខ្លួនធ្វើក្នុងនាមម្ចាស់សិទ្ធិ។

(ទីពីរ) ចំពោះអាណត្តិ អានុភាពនៃកិច្ចសន្យាទិញលក់រថយន្តគឺរវាង អាណត្តិគាហក និង ភាគីអ្នកលក់ ពោលគឺមិនមានផ្ទាល់រវាងអាណត្តិទាយកឡើយ។ ប៉ុន្តែ ចំពោះការតំណាងវិញ អានុភាពនៃកិច្ចសន្យាលក់ទិញរថយន្ត គឺមានរវាង ភាគីអ្នកលក់ និង ម្ចាស់សិទ្ធិ ពោលគឺមិនមានផ្ទាល់រវាងអ្នកតំណាងឡើយ។

(ទីបី) ចំពោះអាណត្តិ ករណីយកិច្ច និង សិទ្ធិ កើតមានផ្ទាល់រវាងភាគីអ្នកលក់ និង អាណត្តិគាហក។ ប៉ុន្តែ ចំពោះការតំណាងវិញ ករណីយកិច្ច និង សិទ្ធិ កើតមានផ្ទាល់រវាងភាគីអ្នកលក់ និង ម្ចាស់សិទ្ធិ។

សិទ្ធិតំណាង មិនមែនមានប្រភពមកពីអាណត្តិតែមួយគត់នោះទេ តែវាអាចកើតចេញពីកិច្ចសន្យាការងារ និង កិច្ចសន្យាម៉ៅការជាដើម។

## ៣.៤. កាតព្វកិច្ចរបស់អាណត្តិគាហក

កាតព្វកិច្ចរបស់អាណត្តិគាហក មានដូចជា ករណីយកិច្ចប្រុងប្រយ័ត្ន ករណីយកិច្ចរាយការណ៍ កាតព្វកិច្ចប្រគល់ ការទទួលខុសត្រូវសងសំណងការខូចខាតដែលបានប្រើប្រាក់ និង ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ ។

### ៣.៤.១. ករណីយកិច្ចប្រុងប្រយ័ត្ន

ករណីយកិច្ចប្រុងប្រយ័ត្នមានចែងក្នុងមាត្រា ៦៤០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

អាណត្តិគាហក មានករណីយកិច្ចចាត់ចែងកិច្ចការអាណត្តិ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដោយផ្អែកតាមអត្ថន័យនៃអាណត្តិ។ ប៉ុន្តែ បញ្ញត្តិនេះមិនរារាំងចំពោះការបន្ថយករណីយកិច្ចប្រុងប្រយ័ត្នរបស់អាណត្តិគាហក តាមការព្រមព្រៀងរបស់គូភាគីឡើយ[៤៤]។

[៤៤] មាត្រា ៦៤០ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

កិច្ចសន្យាអាណត្តិ ដែលបង្កើតឡើងរវាងអាណត្តិទាយក និង អាណត្តិគាហក ត្រូវតែផ្អែកលើទំនាក់ទំនងដែលជឿទុកចិត្តគ្នាទៅវិញទៅមក ហើយអាណត្តិទាយក រំពឹង ក៏ដូចជាជឿជាក់ថា អាណត្តិគាហក មានភាពប៉ុនប្រសព្វពិសេស ឬ ជំនាញក្នុងការដោះស្រាយការងារអោយបានជោគជ័យ។ ហើយចំពោះអាណត្តិគាហកត្រូវតែសម្រេចកិច្ចការដោយសុចរិត និង ប្រុងប្រយ័ត្នដើម្បីការពារផលប្រយោជន៍អាណត្តិទាយក។ ប៉ុន្តែកំរិតនៃករណីយកិច្ចនេះ អាចត្រូវបន្ថយអាស្រ័យទៅតាមការព្រមព្រៀងរបស់ភាគីបាន។

ក្នុងករណីដែលអាណត្តិគាហក ធ្វើផ្ទុយនឹងករណីយកិច្ចប្រុងប្រយ័ត្ន ហើយធ្វើអោយមានការខូចខាតដល់អាណត្តិទាយក អាណត្តិទាយកអាចទាមទារសំណងនៃការខូចខាតនោះពីអាណត្តិគាហកបាន។ នៅក្នុងករណីនេះ ប្រសិនបើ ជាអាណត្តិដោយមិនយកកម្រៃ តុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន[៤៥]។ អត្ថន័យនៃមាត្រានេះ គឺមានន័យថា អាណត្តិគាហកត្រូវតែទទួលខុសត្រូវ ដោយយោងទៅតាមគោលការណ៍មិនអនុវត្តកាតព្វកិច្ច ដែលមានន័យថា ភាគីដែលបង្ករព្យសនកម្ម ត្រូវសងសំណងនៃការខូចខាតទៅអោយភាគីម្ខាងទៀត។ នៅក្នុងករណីនេះ ទាយកអាច រំលាយកិច្ចសន្យា ឬ ទាមទារសំណងនៃការខូចខាតបាន។ ម្យ៉ាងទៀត បើកិច្ចសន្យាអាណត្តិនេះ ជាកិច្ចសន្យាដែលមិនយកកម្រៃ នោះតុលាការអាចបន្ថយចំនួនទឹកប្រាក់សំណងនៃការខូចខាតបាន ព្រោះថា អាណត្តិគាហក មិនបានទទួលផលប្រយោជន៍អ្វីសោះ ពីកិច្ចសន្យាអាណត្តិនេះទេ បើឈរលើគោលការណ៍សមភាពរវាងភាគី។ ដូច្នេះហើយ បានជាបញ្ញត្តិនេះកំណត់ពីភាពខុសគ្នារវាង អាណត្តិដោយយកកម្រៃ និង អាណត្តិដោយមិនយកកម្រៃ។

### ៣.៤.២. ករណីយកិច្ចរាយការណ៍

បើមានការទាមទាររបស់អាណត្តិទាយក អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងអាណត្តិ ទោះបីនៅពេលណាក៏ដោយ ឬ ត្រូវរាយការណ៍អំពីហេតុការណ៍នោះដោយគ្មានការយឺតយ៉ាវនៅក្រោយពេលដែលបានបញ្ចប់អាណត្តិហើយ[៤៦]។ ករណីនេះមានន័យថា គឺជាបន្ទុកមួយទៅលើអាណត្តិគាហក នូវករណីយកិច្ចរាយការណ៍អំពីស្ថានភាពអំពីការចាត់ចែងកិច្ចការអាណត្តិ។ ករណីយកិច្ចនេះ គឺផ្តើមចេញអំពីការប្រុងប្រយ័ត្នក្នុងនាមជាអ្នកធ្វើកិច្ចការដ៏ល្អ។ ដោយសារតែ ករណីយកិច្ចនេះជាបន្ទុកមួយទៅលើអាណត្តិគាហក ពីព្រោះថា អាណត្តិគាហកបានដឹងអំពីដំណើរការនៃកិច្ចការរបស់ខ្លួន ច្បាស់ជាងនរណាទាំងអស់ ដែលអាណត្តិគាហកគឺជាអ្នកឆ្លើយតបទៅនឹងបញ្ហានេះ។

[៤៥] មាត្រា ៦៤០ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៤៦] មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ជាមួយគ្នានេះដែរ មានសំនួរមួយចោទសួរថា តើអាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពដែរ ឬ ទេប្រសិនបើអាណត្តិទាយកមិនបានស្នើសុំ?

ទោះបីជាអាណត្តិទាយក មិនបានស្នើសុំអោយរាយការណ៍ក៏ដោយ ក៏ត្រូវសន្មតថា អាណត្តិគាហកត្រូវរាយការណ៍អំពីស្ថានភាពបច្ចុប្បន្ននៃការចាត់ចែងនោះ នៅពេលណាដែលមានភាពចាំបាច់នោះសំរាប់អាណត្តិទាយក។ នៅក្នុងករណីនេះ វាជាភាពមិនស្មើគ្នាដែល អាណត្តិគាហក បំពានករណីយកិច្ចនេះ ពីព្រោះតែ ការរាយការណ៍ជាករណីយកិច្ចតាមផ្លូវច្បាប់ យោងតាមគោលការណ៍ទូទៅអំពីការមិនអនុវត្តកាតព្វកិច្ច នោះអាណត្តិទាយកអាចរំលាយកិច្ចសន្យា ហើយគាត់អាចទាមទារសំណង នៅក្នុងករណីដែលមានការខូចខាតកើតមានឡើង។

**៣.៤.៣. ភាតព្វកិច្ចប្រគល់**

អាណត្តិគាហកត្រូវប្រគល់ប្រាក់ និង វត្ថុផ្សេងៗទៀតដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិ អោយទៅអាណត្តិទាយក។ អាណត្តិគាហកក៏ត្រូវប្រគល់ផលដែល ប្រមូលបានអោយទៅអាណត្តិទាយកផងដែរ។ សិទ្ធិដែលអាណត្តិគាហកបានលទ្ធកម្ម នៅក្នុងនាមរបស់ខ្លួនដើម្បីអាណត្តិទាយក ត្រូវផ្ទេរសិទ្ធិនោះអោយទៅអាណត្តិទាយកវិញ[៤៧]។

នេះគឺជារឿងធម្មតា ដែលអាណត្តិគាហកត្រូវតែប្រគល់ផល ក៏ ដូចជាលទ្ធកម្មផ្សេងៗទៅអោយអាណត្តិទាយកវិញ ព្រោះថាអាណត្តិទាយកបានប្រគល់សិទ្ធិអំណាចទៅអោយអាណត្តិគាហកចាត់ចែងការងារដើម្បីតែផលប្រយោជន៍ខ្លួន ដូច្នេះនៅពេលដែលអាណត្តិគាហកបញ្ចប់ការងារអាណត្តិគាហកត្រូវប្រគល់ប្រាក់ ឬ វត្ថុផ្សេងៗទៀត ដែលទទួលបានតាមការចាត់ចែងកិច្ចការអាណត្តិអោយទៅអាណត្តិទាយកវិញ។

ជាឧទាហរណ៍ នៅក្នុងករណីដែលអាណត្តិទាយក បានផ្តល់អាណត្តិទៅអោយអាណត្តិគាហក ដើម្បីទិញរថយន្តថ្មីមួយគ្រឿង។ នៅពេលដែលបញ្ចប់កិច្ចការហើយ អាណត្តិគាហកត្រូវតែប្រគល់រថយន្តនោះទៅអាណត្តិទាយកវិញភ្លាម ពោលគឺនៅពេលដែលអាណត្តិគាហក បានទទួលរថយន្តនោះរួចហើយ។

**៣.៤.៤. ការទទួលខុសត្រូវសងសំណងការខូចខាតដែលបានប្រើប្រាក់**

ប្រសិនបើអាណត្តិគាហក បានប្រើប្រាក់ដែលត្រូវប្រគល់ទៅអោយអាណត្តិទាយក ឬ បានប្រើប្រាក់ដែលទុកប្រើសម្រាប់ផលប្រយោជន៍នោះ ដើម្បីខ្លួន ត្រូវបង់ការប្រាក់ដោយគិតពីថ្ងៃដែលបានប្រើប្រាក់នោះ។ ប្រសិនបើមានការខូចខាត ត្រូវទទួលខុសត្រូវសងសំណងនោះ[៤៨]។

[៤៧] មាត្រា ៦៤២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៤៨] មាត្រា ៦៤៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ដោយសាតែប្រាក់ដែលអាណត្តិគាហក ទទួលបានពីតតិយជន ក្នុងកំឡុងពេលដែលចាត់ចែងកិច្ចការ នោះប្រាក់ដែលទទួលបាននោះគឺជាទ្រព្យសម្បត្តិរបស់អាណត្តិទាយក។ ហើយប្រសិនបើ អាណត្តិគាហកប្រើប្រាស់នូវប្រាក់នោះ ដូច្នេះអាណត្តិគាហកត្រូវតែទទួលខុសត្រូវករណីយកិច្ចសងសំណងនៃការខូចខាតទៅអាណត្តិទាយក ប្រសិនបើការប្រើប្រាស់នោះសម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនរបស់អាណត្តិគាហក។ អាណត្តិគាហក មានករណីយកិច្ចសងសំណងនៃការខូចខាត មិនមែនត្រឹមតែជាប្រាក់ក្នុងកំឡុងពេលដែលយឺតយ៉ាវប៉ុណ្ណោះទេ គឺថែមទាំងការខូចខាតដ៏ទៃទៀតប្រសិនបើមាន។

នេះគឺជាទណ្ឌកម្មមួយ ចំពោះការបំពានករណីយកិច្ច ដូចដែលមានចែងក្នុងមាត្រា ៦៤២។ ប្រសិនបើអាណត្តិគាហកបានប្រើនូវវត្ថុដ៏ទៃទៀត ក្រៅពីប្រាក់ ដែលត្រូវប្រគល់អោយអាណត្តិទាយកនោះគាត់ត្រូវទទួលខុសត្រូវចំពោះការ មិនអនុវត្តកាតព្វកិច្ច ឬ អំពើអនីត្យានុកូល។

នៅក្នុងករណីដែលអាណត្តិទាយកគ្មានសិទ្ធិ ទៅលើទ្រព្យនោះ អាណត្តិគាហកត្រូវធ្វើលទ្ធកម្មលើកម្មសិទ្ធិលើប្រាក់ដែលគាត់បានទទួលទាក់ទងនឹងកិច្ចសន្យាអាណត្តិ។ ម្យ៉ាងទៀតអាណត្តិគាហក ក៏មិនចាំបាច់ សងនូវប្រាក់ដដែល ដែលគាត់ទទួលបាននោះទេ ព្រោះថាប្រាក់មានលទ្ធភាពអាចជំនួសនូវប្រាក់ផ្សេងបាន ឬ អាចជំនួសបាន។

### ៣.៤.៥. ករណីយកិច្ចសង្គ្រោះបន្ទាន់នៅក្រោយពេលបញ្ចប់អាណត្តិ

នៅក្នុងករណីដែលបានបញ្ចប់អាណត្តិហើយ ប្រសិនបើមានស្ថានភាពបន្ទាន់ អាណត្តិគាហក សន្តិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់របស់អាណត្តិគាហកនោះ ត្រូវធ្វើការចាត់ចែងដែលចាំបាច់រហូតដល់ពេលដែលអាណត្តិទាយក សន្តិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់អាណត្តិទាយកនោះ អាចចាត់ការកិច្ចការនោះបាន[៤៥]។ ជាទូទៅ ប្រសិនបើអាណត្តិត្រូវបានរំលាយកាតព្វកិច្ច និង សិទ្ធិទាមទារទាំងអស់ត្រូវបានរលត់ ប៉ុន្តែ ចំពោះចំនុចនេះគឺ មានគោលបំណងការពារអាណត្តិទាយក ពីការខូចខាតដែលកើតឡើងពីកិច្ចការណាមួយ ដែលមិនអាចព្យាករណ៍ទុកបាន ក្នុងកំឡុងពេលចាប់ពីការបញ្ចប់អាណត្តិ រហូតដល់អាណត្តិទាយក ឬ អ្នកផ្សេងទៀតទទួលបន្តនូវការចាត់ចែងកិច្ចការអាណត្តិនោះ។

## ៣.៥. កាតព្វកិច្ចរបស់អាណត្តិទាយក

ចំពោះកាតព្វកិច្ចរបស់អាណត្តិទាយក មានដូចជា ករណីយកិច្ចបង់កម្រៃ ករណីយកិច្ចបង់កម្រៃជាមុន ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ ។

[៤៥] មាត្រា ៦៥០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

### ៣.៥.១. ករណីយកិច្ចបង់កម្រៃ

អាណត្តិគាហក ពុំអាចទាមទារកម្រៃចំពោះអាណត្តិទាយកបានឡើយ ក្នុងករណីដែលពុំបានកំណត់ជាពិសេស នៅក្នុងកិច្ចសន្យា[៥០]។ បើគ្មានការកំណត់ពិសេស ដែលត្រូវអោយអាណត្តិទាយកបង់កម្រៃអោយអាណត្តិគាហកនោះទេ នាំអោយអាណត្តិគាហកពុំអាចទាមទារបានឡើយ ព្រោះថា ជាគោលការណ៍កិច្ចសន្យាអាណត្តិ មិនយកកម្រៃ។ ដូច្នេះ ប្រសិនបើអាណត្តិគាហកចង់បានកម្រៃតាមរយៈកិច្ចការអាណត្តិ នោះអាណត្តិគាហក ត្រូវបង្កើតកិច្ចព្រមព្រៀងពិសេស ឬ ការចរចារផ្សេងៗ មុននឹងបង្កើតកិច្ចសន្យាអាណត្តិនោះ។

នៅក្នុងករណីនៃអាណត្តិដោយយកកម្រៃ អាណត្តិគាហកមិនអាចទាមទារកម្រៃបានឡើយ បើមិនបានបញ្ចប់ការអនុវត្តករណីយកិច្ចដែលត្រូវតាមអាណត្តិនោះរួចហើយទេ។ ប៉ុន្តែ បើបានកំណត់កម្រៃតាមអំឡុងពេល អាចទាមទារបាន នៅក្រោយពេលដែលអំឡុងពេលនោះបានកន្លងផុត[៥១]។ ជាទូទៅនៅក្នុងករណីដែលអាណត្តិយកកម្រៃ អាណត្តិទាយកមិនចាំបាច់បង់កម្រៃមុនការអនុវត្តទេ មានន័យថា អាណត្តិទាយក អាចបង់កម្រៃ នៅក្រោយពេលបញ្ចប់ការងារក៏បាន។ ប៉ុន្តែ បើមានការព្រមព្រៀងផ្សេងពីនេះ ដូចជា ការកំណត់រយៈពេលក្នុងការបង់កម្រៃ នោះពេលផុតរយៈពេលនោះ អាណត្តិទាយកត្រូវបង់កម្រៃទៅអាណត្តិគាហកតាមការព្រមព្រៀង។

បើអាណត្តិត្រូវបានបញ្ចប់ការអនុវត្ត នៅពាក់កណ្តាលទី ដោយសារមូលហេតុដែលមិនមែនជាការទទួលខុសត្រូវរបស់អាណត្តិគាហក អាណត្តិគាហកអាចទាមទារកម្រៃបាន តាមសមាមាត្រនៃភាគរយដែលបានអនុវត្តរួចហើយនោះ[៥២]។ នេះបង្ហាញថា ប្រសិនបើអាណត្តិត្រូវបានបញ្ចប់អាណត្តិនៅពាក់កណ្តាលទី ដែលមិនមែនជាកំហុសរបស់អាណត្តិគាហក នាំអោយអាណត្តិគាហកអាចទាមទារកម្រៃបាន តាមសមាមាត្រដែលបានអនុវត្តរួច ព្រោះថាគោលបំណងរបស់អាណត្តិគឺមិនមែនសម្រេចការងារដែលបានកំណត់ ដែលតម្រូវជាដាច់ខាតដូចកិច្ចសន្យាម៉ៅការ (កាតព្វកិច្ចសម្រេចលទ្ធផល) នោះទេ។

### ៣.៥.២. ករណីយកិច្ចបង់សោហ៊ុយជាមុន

ប្រសិនបើមានតម្រូវការចាំបាច់លើសោហ៊ុយ សម្រាប់ការចាត់ចែងកិច្ចការអាណត្តិ អាណត្តិទាយកត្រូវបង់សោហ៊ុយនោះជាមុន តាមការទាមទាររបស់អាណត្តិគាហក[៥៣]។

[៥០] មាត្រា ៦៤៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៥១] មាត្រា ៦៤៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៥២] មាត្រា ៦៤៤ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

[៥៣] មាត្រា ៦៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

ករណីយកិច្ចរបស់អាណត្តិទាយកក្នុងការបង់សោហ៊ុយនេះ គឺមានគោលបំណងចង់អោយការចាត់ចែងកិច្ចការអាណត្តិ ដំណើរការប្រព្រឹត្តិទៅប្រកបដោយភាពរលូន។ ម្យ៉ាងទៀត ទោះបីជាកិច្ចសន្យាអាណត្តិ ជាកិច្ចសន្យាដែលយកកម្រៃ ឬ មិនយកកម្រៃក៏ដោយ អាណត្តិគាហកនៅតែអាចទាមទារកម្រៃជាមុនបាន ព្រោះថាកិច្ចសន្យាអាណត្តិនោះ នឹងចំណាយធនធានខ្លះៗ សម្រាប់បំពេញកិច្ចការអាណត្តិនោះ។ ឬ អាចនិយាយម្យ៉ាងទៀតថា អាណត្តិគាហក យកធនធានរបស់អាណត្តិទាយក ទៅបំរើផលប្រយោជន៍អោយអាណត្តិទាយក មិនមែនយកធនធានរបស់ខ្លួនទៅបំរើផលប្រយោជន៍ អោយអ្នកផ្សេងឡើយ ដែលនេះ គឺជាគោលការណ៍សមធម៌សម្រាប់ការពារភាគីទាំងសងខាង នៅក្នុងកិច្ចសន្យាអាណត្តិ។

### ៣.៥.៣. ករណីយកិច្ចសងវិញនូវសោហ៊ុយដែលបានចំណាយ

ដោយយោងទៅតាមមាត្រា ៦៤៥ អាណត្តិគាហកអាចទាមទារសោហ៊ុយពីអាណត្តិទាយកជាមុនបាន។ ផ្ទុយមកវិញបើយោងទៅតាមស្មារតី នៃមាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានសំដៅថា បើទោះបីជាអាណត្តិគាហក មិនបានស្នើសុំអោយអាណត្តិទាយកបង់សោហ៊ុយជាមុននោះទេ ប៉ុន្តែអាណត្តិគាហក មានសិទ្ធិទាមទារនូវសោហ៊ុយដែលបានចំណាយ និង ការប្រាក់ពីអាណត្តិទាយកបានដែរ ប្រសិនបើអាណត្តិគាហកបានប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួនសម្រាប់ចាត់ចែងកិច្ចការអាណត្តិ ដែលជាប្រយោជន៍របស់អាណត្តិទាយកនោះ។

ជាមួយគ្នានេះដែរប្រសិនបើ អាណត្តិគាហកបានអនុវត្តកាតព្វកិច្ចចាំបាច់ដើម្បីចាត់ចែងកិច្ចការអាណត្តិ នោះអាណត្តិគាហកអាចទាមទារអោយអាណត្តិទាយកសងនូវកាតព្វកិច្ចនោះជំនួសខ្លួនបាន។ បើទោះបីជា អាណត្តិទាយកគ្មានកំហុសក៏ដោយក៏ ត្រូវតែទទួលខុសត្រូវដែរ ដែលមានន័យថា មិនចាំបាច់មានកំហុសរបស់អាណត្តិទាយក ទើបអាចទាមទារអោយអាណត្តិទាយកទទួលខុសត្រូវនោះទេ។

ទន្ទឹមនឹងនេះដែរ បើយោងតាមមាត្រា ៦៤៦ កថាខណ្ឌទី ៣ ប្រសិនបើមានការខូចខាតកើតឡើង តែមិនមែនជាកំហុសរបស់អាណត្តិគាហក នោះអាណត្តិគាហកអាចទាមទារសំណងនៃការខូចខាតពីអាណត្តិទាយកបាន។ នេះគឺជាការទទួលខុសត្រូវដាច់ខាតរបស់អាណត្តិទាយក ព្រោះអាណត្តិទាយកគឺជាអ្នកដែលទទួលរងនូវហានិភ័យនេះ។ ប៉ុន្តែ ប្រសិនបើការកើតឡើងនូវការខូចខាតជាកំហុសរបស់តតិយជនណាមួយ នោះ អាណត្តិគាហក អាណត្តិគាហកអាចទាមទារសំណងពីអាណត្តិទាយកបានដែលកំរិតត្រឹមតែលទ្ធភាពនៃសំណង ពី តតិយជនតែប៉ុណ្ណោះ។

## ៣.៦. ការរំលាយកិច្ចសន្យាអាណត្តិ

ការរំលាយកិច្ចសន្យាអាណត្តិ គឺមានមូលហេតុនៃការរំលាយដែលនឹងមានការបកស្រាយពីមូលហេតុទាំងនេះយ៉ាងច្បាស់លាស់នាខាងក្រោមនេះ ព្រមទាំងមានការបកស្រាយអំពីអានុភាពនៃការរំលាយផងដែរ។

### ៣.៦.១. មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ

មូលហេតុនៃការបញ្ចប់កិច្ចសន្យាអាណត្តិ មានពីរប្រភេទគឺ ការបញ្ចប់ដោយការរំលាយកិច្ចសន្យាអាណត្តិ និង ការបញ្ចប់ដោយផ្អែកទៅលើមូលហេតុផ្សេងៗ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះចំណុចទាំងពីរ នេះ នឹងបកស្រាយអោយបានច្បាស់លាស់ខាងក្រោមនេះ ៖

#### ៣.៦.១.១. ការបញ្ចប់ដោយការរំលាយកិច្ចសន្យាអាណត្តិដោយភាគី

ជាទូទៅ ការរំលាយកិច្ចសន្យាអាណត្តិ អាចធ្វើនៅពេលណាក៏បាន ព្រោះវាជាបញ្ញត្តិដែលកំណត់ពិសេស។ លើសពីនេះទៅទៀត កិច្ចសន្យាអាណត្តិ គឺ ពឹងផ្អែកលើការជឿជាក់គ្នាទៅវិញទៅមក ក៏ដូចជាពឹងផ្អែកលើទំនាក់ទំនង នៃការទុកចិត្តគ្នាទៅវិញទៅមកផងដែរ ប៉ុន្តែ ប្រសិនបើភាគីណាម្ខាងបានបាត់បង់ការទុកចិត្តលើភាគីម្ខាងទៀត ឬ ភាគីទាំងសងខាងបាត់បង់ទំនុកចិត្តលើគ្នា នោះពួកគេមិនអាចថែរក្សាទំនាក់ទំនងនោះបានទៀតទេ ដូច្នេះ ភាគីនីមួយៗអាចរំលាយកិច្ចសន្យាអាណត្តិបាន នៅពេលណាក៏បានដោយមិនចាំបាច់មានហេតុផលសមរម្យ (មាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណី )។

ម៉្យាងទៀត បើការរំលាយកិច្ចសន្យាអាណត្តិនោះ ធ្វើអោយមានការខូចខាតដល់ភាគីម្ខាងទៀត នោះភាគីដែលបង្ករការខូចខាតត្រូវសងសំណងនៃការខូចខាតទៅភាគីម្ខាងទៀត។ ប៉ុន្តែ ក៏អាចមានករណីផ្សេងពីនេះ ផងដែរ។ **ឧទាហរណ៍**ដូចជា ប្រសិនបើអាណត្តិគាហករំលាយកិច្ចសន្យា ដែលធ្វើអោយខូចខាតផលប្រយោជន៍របស់ អាណត្តិទាយក ព្រោះកិច្ចការនោះគ្មានអាណត្តិគាហកថ្មីណាអាចមកធ្វើបន្តបានឡើយ ដូច្នេះ ប្រសិនបើមានការខូចខាតផលប្រយោជន៍ដល់អាណត្តិទាយក នោះអាណត្តិគាហកត្រូវ សងសំណងនៃការខូចខាតទៅអាណត្តិទាយក។ **ឧទាហរណ៍**មួយទៀតដូចជាករណី ដែល អាណត្តិគាហករំលាយកិច្ចសន្យា ដោយសារមិនអាចបន្តទៀតបានដោយមូលហេតុគ្រោះថ្នាក់ចរាចរណ៍ ឬ មានជំងឺ នោះអាណត្តិគាហកមិនចាំបាច់សងសំណងនៃការខូចខាតនោះទេ។

#### ៣.៦.១.២. ការបញ្ចប់ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី

ដោយយោងទៅតាមស្មារតីនៃមាត្រា ៦៤៩ កថាខណ្ឌទី១ បានចែងថា ក្រៅពីការរំលាយកិច្ចសន្យាអាណត្តិដោយបញ្ញត្តិនៃមាត្រា ៦៤៧ ( ការរំលាយកិច្ចសន្យាអាណត្តិ ) នៅមានមូលហេតុមួយចំនួនផ្សេងៗទៀតដូចខាងក្រោម ៖

-មរណភាពរបស់អាណត្តិទាយក ឬ អាណត្តិគាហក

-ការប្រកាសក្ស័យធនរបស់អាណត្តិទាយក ឬ អាណត្តិគាហក

-ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ឬ ការប្រកាសការចាប់ផ្តើមហិតូបត្ថរបស់អាណត្តិទាយក ឬ អាណត្តិគាហក

-អាណត្តិទាយក ឬ អាណត្តិគាហក ជានីតិបុគ្គលបានរលាយ ឬ បានរួមបញ្ចូលជាមួយនីតិបុគ្គលផ្សេង

-មូលហេតុផ្សេងៗ ដែលបានកំណត់តាមការព្រមព្រៀងរបស់ភាគី។

ដោយសំគាល់ឃើញថា បញ្ញត្តិខាងលើនេះមិនមែនជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ ដូច្នេះភាគីអាចមានជំរើសច្រើនក្នុងការរំលាយកិច្ចសន្យា ដោយអនុលោមទៅតាមមូលហេតុខាងលើក៏បាន ឬ អាចបង្កើតកិច្ចព្រមព្រៀងថ្មីផ្សេងពីនេះ សម្រាប់ធ្វើជាមូលហេតុក្នុងការរំលាយក៏បាន។

### ៣.៦.២. អានុភាពនៃការរំលាយ

បើយោងទៅតាមស្មារតីនៃមាត្រា ៦៥៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ បានសំដៅថា អានុភាពនៃការរំលាយ កើតមានឡើងដែលឆ្ពោះទៅអនាគតតែប៉ុណ្ណោះ ហើយមិនមានអានុភាពប្រតិសកម្មទេ។ មូលហេតុដែលបណ្តាលអោយការរំលាយកិច្ចសន្យាអាណត្តិ មិនមានអានុភាពប្រតិសកម្ម ព្រោះថា បើសិនជាវាមានអានុភាពប្រតិសកម្ម នោះទំនាក់ទំនងរវាង អាណត្តិទាយក និង អាណត្តិគាហក និង ភាគីម្ខាងទៀត ប្រាកដជាមានភាពស្មុគស្មាញ ដែលពិបាក នឹងដោះស្រាយជាក់ជាមិនខាន។

ដូច្នេះហើយ ប្រសិនបើកិច្ចសន្យាត្រូវបានបញ្ចប់ អាណត្តិគាហក ត្រូវប្រគល់ប្រាក់ ឬ វត្ថុផ្សេងៗដែលខ្លួនបានទទួលពីផលនៅក្នុងកិច្ចការអាណត្តិ អោយទៅអាណត្តិទាយក ហើយជាមួយគ្នានេះដែរ អាណត្តិទាយក ត្រូវបង់កម្រៃ ឬ សោហ៊ុយផ្សេងៗ ទៅអោយអាណត្តិគាហក តាមសមាមាត្រនៃភាគដែលបានអនុវត្តរួចហើយ។

មូលហេតុនៃការបញ្ចប់អាណត្តិ ទោះបីជាមូលហេតុនោះកើតឡើងចំពោះអាណត្តិទាយកក៏ដោយ ឬ ចំពោះអាណត្តិគាហកក៏ដោយ ពុំអាចយកមកតតាំងនឹងភាគីម្ខាងទៀតបានឡើយ បើមិនបានជូនដំណឹងអោយភាគីម្ខាងទៀត ឬ បើភាគីម្ខាងទៀតពុំបានដឹងអំពីមូលហេតុនោះទេ [៥៤] ។ ចំពោះចំនុចនេះ មានគោលបំណងដើម្បីការពារភាគីនៃកិច្ចសន្យាអាណត្តិ ដែលមិនដឹងអំពីការបញ្ចប់អាណត្តិ ពីការខូចខាតដែលមិនអាចព្យាករណ៍ទុកបាន។ ដូច្នេះប្រសិនបើភាគីណាមួយដែលបានបញ្ចប់អាណត្តិ ដែលមិនបានជូនដំណឹងដល់ភាគីម្ខាងទៀតទេ នោះគាត់ មិនអាចលើកយកមូលហេតុនៃការបញ្ចប់អាណត្តិនេះ មកតតាំងនឹងភាគីម្ខាងទៀតបានឡើយ។

[៥៤] មាត្រា ៦៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧

# ជំពូក ៤ កិច្ចសន្យាដឹកជញ្ជូន

ការដឹកជញ្ជូនក៏ជាផ្នែកមួយ ដែលបង្កើតឱ្យមានកិច្ចសន្យាគតិយុត្តិមួយផងដែរ ក៏ប៉ុន្តែចំពោះកិច្ចសន្យាដឹកជញ្ជូននេះវាមានលក្ខណៈខុសប្លែកមួយចំនួន រវាងកិច្ចសន្យាដ៏ទៃផ្សេងទៀតដែលនៅក្នុងកិច្ចសន្យាដឹកជញ្ជូននេះ នឹងបកស្រាយនូវចំនុចសំខាន់ៗមួយចំនួន ដូចជា និយមន័យនៃកិច្ចសន្យាដឹកជញ្ជូនដែលរួមផ្សំជាមួយនឹង សញ្ញាណទូទៅផងដែរ។ នៅក្នុងកិច្ចសន្យាដឹកជញ្ជូននឹងធ្វើការចែងចែកជាពីរផ្នែកធំៗ គឺ ការដឹកជញ្ជូនទំនិញ និង ការដឹកជញ្ជូនអ្នកដំណើរ ដែលចំណុចចទាំងអស់នេះនឹងត្រូវបកស្រាយនៅខាងក្រោមនេះ។

## ៤.១. សញ្ញាណទូទៅ និង និយមន័យ នៃកិច្ចសន្យាដឹកជញ្ជូន

កិច្ចសន្យាដឹកជញ្ជូន ជាកិច្ចសន្យាដែលអ្នកដឹកជញ្ជូនសន្យាដឹកអ្នកដំណើរ ភារៈវត្ថុ ឬ ទំនិញពីកន្លែងមួយទៅកន្លែងមួយទៀត ដោយយកថ្លៃតាមការព្រមព្រៀង ឬ តាមថ្លៃកំណត់ដោយរដ្ឋ[៥៥] ។ រីឯសញ្ញាណ នៃការដឹកជញ្ជូនដែលកំណត់ដោយសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មបានព្រាងជាសញ្ញាណថា កិច្ចសន្យាបែបនេះ សំដៅដល់កិច្ចសន្យាដែលពាណិជ្ជករម្នាក់ហៅថាអ្នកដឹកជញ្ជូនធ្វើការដឹកជញ្ជូន ទំនិញ ឬ ដឹកជញ្ជូនអ្នកដំណើរ ពីកន្លែងមួយទៅកន្លែងមួយទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមផ្លូវទឹក តាមផ្លូវគោកដោយទទួលថ្លៃឈ្នួលពីការដឹកជញ្ជូននោះ[៥៦] ។

មធ្យោបាយដឹកជញ្ជូនមានច្រើនប្រភេទ ដែលអាចជំរុញអោយសកម្មភាពដឹកជញ្ជូនមានភាពរហ័ស ឬ យឺតយ៉ាវ។ ផ្លូវដែលអាចដឹកជញ្ជូនបានមានដូចជាផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសជាដើម។ កិច្ចសន្យាដឹកជញ្ជូន ជាកិច្ចសន្យាដែលធ្វើឡើងដោយអ្នកដំណើរជាមួយនឹងអ្នកដឹកជញ្ជូនដែលជាអ្នកយល់ដឹងអំពីគោលការណ៍នៃការដឹកជញ្ជូនអ្នកដំណើរ ឬ ទ្រព្យសម្បត្តិពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀត ហើយអ្នកដំណើរមានកាតព្វកិច្ចបង់ថ្លៃតប នឹង **អ្នករៀបចំអ្នកដំណើរ** ។

**អ្នករៀបចំការធ្វើដំណើរ** សំដៅដល់ពាណិជ្ជករ ឬ តំណាងពាណិជ្ជករដែលអនុវត្តកិច្ចសន្យាដឹកជញ្ជូនក្នុងនាមខ្លួនផ្ទាល់ ឬ ក្នុងនាមក្រុមហ៊ុន ដើម្បីផ្តល់សេវាក្នុងតម្លៃណាមួយដែលរួមផ្សំដោយសេវាដឹកជញ្ជូន ឬ សេវាផ្សេងៗទៀត[៥៧] ។ ជាទូទៅ ការដឹកជញ្ជូនអ្នកដំណើរ ក៏ដូចជាការដឹកជញ្ជូនទំនិញ ពេលខ្លះមិនមានភាពងាយស្រួលនោះទេ ជួនកាលជួបនូវឧបសគ្គផ្សេងៗ ដែលតម្រូវអោយអ្នករៀបចំការធ្វើដំណើរមានការឆ្នៃប្រឌិតផ្សេងដើម្បីទទួលបាននូវភាពងាយស្រួល និង

[៥៥] មាត្រា ៨៣ នៃក្រិត្យច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាលេខ ៣៨ ក្រ.ច ឆ្នាំ ១៩៨៨
[៥៦] មាត្រា ១២៩ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១
[៥៧] មាត្រា ១៣០ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

ជោគជ័យ។ ចំពោះមធ្យោបាយផ្សេងៗ ក្នុងការបង្ករភាពងាយស្រួលគឺ **ការដឹកជញ្ជូនបន្ត** និង **ការដឹកជញ្ជូនផ្សំគ្នា** ឬ មធ្យោបាយដំទៃផ្សេងៗទៀត ដែលបង្ករជាគុណប្រយោជន៍ ឬ លក្ខណៈសន្សំសំចៃជាដើម។

**ការដឹកជញ្ជូនបន្ត** សំដៅដល់ការប្រតិបត្តិដោយអ្នកដឹកជញ្ជូនច្រើននាក់តាមការទទួលបន្តដោយប្រើប្រាស់មធ្យោបាយនៃការដឹកជញ្ជូនដូចគ្នា[៥៨] ។ **ការដឹកជញ្ជូនផ្សំគ្នា** សំដៅដល់ការប្រតិត្តិដោយអ្នកដឹកជញ្ជូនជាច្រើននាក់ តាមការទទួលបន្តដោយប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្សេងគ្នា[៥៩]។

## ៤.២. ការដឹកជញ្ជូនទំនិញ

ការដឹកជញ្ជូនទំនិញ ត្រូវចាប់ផ្តើមពីពេលដែលអ្នកត្រូវដឹកជញ្ជូនទទួលទំនិញដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួនរហូតដល់ពេលប្រគល់ទំនិញនោះដល់អ្នកទទួល[៦០] ។

កិច្ចសន្យាដឹកជញ្ជូនត្រូវបានប្រើប្រាស់ជាញឹកញាប់ចំពោះអាជីវករ ពាណិជ្ជករ ក្នុងការប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន ការដឹកជញ្ជូនទ្រព្យសម្បត្តិជាដើម។ ចំពោះកិច្ចសន្យាដឹកជញ្ជូនទ្រព្យសម្បត្តិ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដែលមានកំណត់អំពីការទទួលខុសត្រូវ ចំពោះការទទួលយកទ្រព្យសម្បត្តិទាំងនោះមកដឹកជញ្ជូន ក្រោមការគ្រប់គ្រងរបស់ខ្លួន។ ម្យ៉ាងទៀត ភាគីនៃកិច្ចសន្យាដឹកជញ្ជូនទ្រព្យសម្បត្តិនឹងត្រូវបង្ហាញភស្តុតាងនៃកិច្ចសន្យា ជាលាយលក្ខណ៍អក្សរ និងវិក្កយបត្របង់ប្រាក់ ដែលត្រូវកំណត់អំពីឈ្មោះអ្នកដឹកជញ្ជូន និងអ្នកទទួលប្រាក់ពីបុគ្គលដែលជាអ្នកទទួលខុសត្រូវបង់ថ្លៃដឹកទំនិញ ឬ ទ្រព្យសម្បត្តិនោះ។ វិក្កយបត្របង់ប្រាក់ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ហើយត្រូវកម្រិតអំពីទីកន្លែង កាលបរិច្ឆេទនៃការទទួលប្រាក់ ឬ ទ្រព្យសម្បត្តិរួមជាមួយចំណុចនៃប្រភពដើម និង គោលការណ៍ ហើយការគិតថ្លៃដឹកជញ្ជូន គឺត្រូវមើលទៅលើចំនួនរង្វាស់រង្វាល់ ឬ ទម្ងន់ និងលក្ខខណ្ឌនៃទ្រព្យនោះ ដែលអាចមើលឃើញនឹងភ្នែក ។ លើសពីនេះទៅទៀត កិច្ចសន្យាដឹកជញ្ជូនទ្រព្យសម្បត្តិ ក៏មានកម្រិតនូវករណីទទួលខុសត្រូវចំពោះការបាត់បង់ និងព្យសនកម្មការខូចខាតទ្រព្យសម្បត្តិ និងហានិភ័យផ្សេងៗជាដើម។ វិក្កយបត្របង់ប្រាក់គឺមិនត្រូវបានធ្វើការចរចារសាជាថ្មីនោះទេ លើកលែងតែមានបទបញ្ញាតិច្បាប់ផ្សេង ដែលកំណត់ដាច់ដោយឡែក ឬ ក្នុងការព្រមព្រៀងនៃភាគីទាំងពីរក្នុងកិច្ចសន្យាការចរចារលើវិក្កយបត្របង់ប្រាក់នេះ ត្រូវបានចារនៅលើខ្នងដែលមានអនុភាពចំពោះការទទួលយល់ព្រមពីអ្នកដឹកជញ្ជូន។

---

[៥៨] មាត្រា ១៣១ កថាខណ្ឌទី១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[៥៩] មាត្រា ១៣១ កថាខណ្ឌទី២ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[៦០] មាត្រា ១៣២ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

អញ្ញាតប័ណ្ណ ត្រូវធ្វើឡើងជាច្រើនច្បាប់ដោយអ្នកដឹកជញ្ជូន។ អ្នកដឹកជញ្ជូនត្រូវរក្សាទុកមួយច្បាប់ អ្នកផ្ញើត្រូវរក្សាទុកមួយច្បាប់ ហើយមួយច្បាប់ទៀតត្រូវបានភ្ជាប់នឹងទំនិញរហូតដល់ចំណុចគោលដៅ[៦១]។ ដែលមានន័យថា វិក្កយបត្រត្រូវធ្វើឡើងជាច្រើនច្បាប់ ដែលក្នុងនោះ ០១ ច្បាប់ ត្រូវប្រគល់អោយអ្នកដឹកជញ្ជូន និងច្បាប់ដទៃទៀត គឺក្រុមហ៊ុនដឹកជញ្ជូនជាអ្នកថែរក្សាទុក ហើយច្បាប់ដទៃទៀតដែលបានថតចម្លងត្រូវទុកជាភស្តុតាងនៃការទទួលដឹកជញ្ជូន ប្រសិនបើគ្មានភស្តុតាងផ្ទុយពីនេះ។ ជាទូទៅគោលការណ៍នៃប្រតិបត្តិការនៃការលុបចោលវិក្កយបត្រមបង់ប្រាក់ គឺមានអានុភាពដោយសារការចារនៅលើខ្នងវិក្កយបត្រនោះ ដោយសារនៅក្នុងនាមខ្លួន ដោយការកំណត់ពីឈ្មោះ ឬ បញ្ហាពាក់ព័ន្ធទាំងឡាយផ្សេងៗ ។

## ៤.៣. ការដឹកជញ្ជូនអ្នកដំណើរ

ការដឹកជញ្ជូនអ្នកដំណើរ ត្រូវគិតចាប់ពីពេលឡើងជិះរហូតដល់ពេលចុះពីមធ្យោបាយដឹកជញ្ជូន[៦២] ។

កិច្ចសន្យាដឹកជញ្ជូនអ្នកដំណើរ គឺជាកិច្ចសន្យាប្រតិបត្តិដោយអ្នកទទួលដឹកជញ្ជូនអ្នកដំណើរ និង អ្នកដំណើរដោយប្រព្រឹត្តទៅតាមមធ្យោបាយមួយចំនួន ដូចជា តាមរថយន្ត តាមនាវា តាមមធ្យោបាយរថភ្លើង ឬ តាមយន្តហោះជាដើម ដែលមធ្យោបាយទាំងនោះដែលត្រូវបានទទួលស្គាល់ដោយច្បាប់។ គោលដៅនៃកិច្ចសន្យានេះគឺការទទួល ដឹកអ្នកដំណើរដឹកជញ្ជូនទំនិញឱ្យទៅដល់គោលដៅប្រកបដោយសុវត្ថិភាព និងទទួលខុសត្រូវបំពេញកាតព្វកិច្ចផ្សេងៗទៀត ម្យ៉ាងទៀតអ្នកដឹកជញ្ជូនត្រូវទទួលស្គាល់ចំពោះការខូចខាត ឬ ការបាត់បង់ចំពោះអ្នកដំណើរ និងការរងគ្រោះថ្នាក់ចំពោះអ្នកដំណើរផងដែរ លើកលែងតែការខូចខាត ឬ ការរងរបួសនោះកើតឡើងដោយកំហុសរបស់អ្នកដំណើរផ្ទាល់។ ម្យ៉ាងវិញទៀត អ្នកដឹកជញ្ជូនមិនត្រូវទទួលខុសត្រូវចំពោះការបាត់បង់រាល់ឯកសារ ប្រាក់កាស ឬ ទ្រព្យសម្បត្តិមានតម្លៃផ្សេងៗទៀត លើកលែងតែអ្នកដឹកជញ្ជូនទ្រព្យសម្បត្តិនោះដែលអ្នកដំណើរបានអះអាងបញ្ជាក់ ។

អ្នកដឹកជញ្ជូនមិនទទួលខុសត្រូវចំពោះឥវ៉ាន់យួរដែលបាត់បង់ ឬ អ្វីៗផ្សេងទៀតដែលពាក់ព័ន្ធជាមួយឥវ៉ាន់ទាំងនោះ លើកលែងតែអ្នកដំណើរបានបង្ហាញនូវកំហុសរបស់អ្នកដឹកជញ្ជូនផ្ទាល់តែប៉ុណ្ណោះ។ ក្នុងករណីមានប្រធានសក្តិ ឬ មានវិការៈដែលកើតឡើងពីកំហុសរបស់អ្នកដំណើរផ្ទាល់ អ្នកដឹកជញ្ជូនមិនត្រូវទទួលខុសត្រូវឡើយ។

---

[៦១] មាត្រា ១៣៤ កថាខណ្ឌទី១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[៦២] មាត្រា ១៥១ នៃសេចក្តីព្រាងច្បាប់ស្តីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

ករណីខ្លះនៅមានពេល មានករណីដឹកជញ្ជូនបន្តគ្នា ដែលអ្នកដឹកជញ្ជូនបន្តឱ្យអ្នកដឹកជញ្ជូនផ្សេងទៀតដឹកជញ្ជូន ឬ មានការបញ្ចូលរួមគ្នា ហើយមានការបាត់បង់ខូចខាត ឬ ការរងរបួសកើតឡើង អ្នកដឹកជញ្ជូនទាំងនោះត្រូវទទួលខុសត្រូវលើបញ្ហាទាំងនោះត្រូវទទួលខុសត្រូវលើបញ្ហាទាំងនោះ លើកលែងតែមានអ្នកដឹកជញ្ជូនណាម្នាក់ក្នុងចំណោមអ្នកដឹកជញ្ជូនទាំងនោះ បានបញ្ជាក់អំពីការទទួលខុសត្រូវទាំងស្រុងលើប្រតិបត្តិការដឹកជញ្ជូននោះ[៦៣] ។

## ៤.៤. ការបញ្ចប់កិច្ចសន្យាដឹកជញ្ជូន

កិច្ចសន្យាដឹកជញ្ជូនអាចត្រូវបានរំលាយ ឬ ត្រូវបានបញ្ចប់ ដោយយោងតាមកិច្ចសន្យាដឹកជញ្ជូននោះ[៦៤] ។ មានន័យថា កិច្ចសន្យាដឹកជញ្ជូននោះ ត្រូវបានបញ្ចប់នៅពេលអ្នកដឹកជញ្ជូនបានបញ្ចប់នូវកិច្ចការរបស់ខ្លួន។

[៦៣] មាត្រា ១៥៥ នៃសេចក្ដីព្រាងច្បាប់ស្ដីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

[៦៤] មាត្រា ១៥៧ នៃសេចក្ដីព្រាងច្បាប់ស្ដីពី កិច្ចសន្យាពាណិជ្ជកម្ម ឆ្នាំ ២០១១

# សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ឆ្លងតាមការសិក្សាស្រាវជ្រាវ និង ធ្វើការបកស្រាយនូវប្រធានបទដែលទាក់ទងទៅនឹងចំណងគតិយុត្តិតាមកិច្ចសន្យា ដែលមានទំនាក់ទំនងទៅនឹងសេវាកម្ម ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការរស់នៅប្រចាំថ្ងៃ ក៏ដូចជាសារៈសំខាន់សម្រាប់សកម្មភាពអាជីវកម្មផងដែរ។ បុគ្គលម្នាក់ៗមិនអាចជៀសពីសេវាកម្មបានឡើយ ដែលទាមទារឱ្យមានការធានាចំពោះសេវាដែលបានបំរើទៅអតិថិជនថានឹងមានគុណភាពល្អ និង លទ្ធផលល្អ និង ជាពិសេសគឺទាន់ពេលវេលា និងទាន់ចិត្តជូនអ្នកទទួលសេវានោះផងដែរ។ ក៏ប៉ុន្តែការបំរើសេវាកម្មផ្សេងៗ មិនសុទ្ធសឹងតែមានលក្ខណៈវិជ្ជមានទាំងស្រុងនោះទេ។ បើយើងសង្កេតទៅលើសកម្មភាពរបស់អាជីវករនោះយើងពិតជាមើលឃើញនូវចំនុចខ្វះខាតមួយចំនួន ដែលតែងតែកើតមានឡើងតាមរយៈការឆ្លុះបញ្ចាំងទៅលើសកម្មភាពផ្សេងៗ ដូចជា ប្រតិបត្តិការនៃសេវាកម្មដឹកជញ្ជូន មៅការ ដែលប្រតិបត្តិករមិនទាន់បានអនុវត្តឱ្យមានភាពប្រសើរនៅឡើយ ៖ ករណីដូចជាការត្អូញត្អែររបស់អ្នកដំណើរតាមរថយន្តក្រុងនានាពីភ្នំពេញទៅខេត្ត ពីភ្នំពេញទៅក្រុងហូជីមិញ ពីភ្នំពេញទៅប្រទេសថៃ ជាដើម។ លើសពីនេះទៅទៀតបញ្ហាក៏កើតឡើងផងដែរទាក់ទងនឹងអាជីវកម្មនៃសេវាកម្មមៅការ ដែលតែងតែកើតឡើងនូវការអាក់អន់ស្រពន់ចិត្ត រហូតដល់ទំនាស់ពាក្យសំដីផ្សេងៗ ដូចជា អ្នកមៅការមិនបានអនុវត្តឱ្យទាន់ពេលវេលា ឬ ការប្រគល់លទ្ធផលខុសពីការព្រមព្រៀង។

អាស្រ័យហេតុនេះ ដើម្បីអនុវត្តទៅលើសកម្មភាពសេវាកម្មឱ្យកាន់តែប្រសើរឡើង ប្រតិបត្តិករ អាជីវករ ភាគីចុះកិច្ចសន្យា គួរតែ ៖

-បង្កើតកិច្ចសន្យាដោយបង្ហាញនូវឆន្ទៈដោយពិតប្រាកដ និង ដោយសេរី ជៀសវាងនូវវិការៈទាំងឡាយដូចជា ការភាន់ច្រឡំ ការឆបោក ការកេងចំនេញហួសហេតុជាដើម។

-ភាគីនៃកិច្ចសន្យាត្រូវតែគោរពកាតព្វកិច្ចដែលបង្កើតឡើងដោយឆន្ទៈសងខាង។

-ក្នុងករណីដែលកិច្ចសន្យាសេវាកម្មមួយចំនួន ដែលមានលក្ខណៈពិសេសដាច់ដោយឡែកនិតិនិពន្ធ គួរតែស្រាវជ្រាវចងក្រងបង្កើតជាបទដ្ឋានគតិយុត្តជាក់លាក់ផ្សេងពីកិច្ចសន្យាសេវាកម្មដែលមានរួចជាស្រេចនៅក្នុងក្រមរដ្ឋប្បវេណី ជាពិសេសការផ្តោតអារម្មណ៍យកចិត្តទុកដាក់ ជំរុញដល់ការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្មឱ្យបានឆាប់រហ័ស ដើម្បីសម្រួលដល់ការអនុត្តរបស់អាជីវករ និងពាណិជ្ជករ។

-ចំពោះក្រសួងដែលពាក់ព័ន្ធ រួមមានដូចជា ក្រសួងសាធារណៈការ និងដឹកជញ្ជូន រួមទាំងក្រសួងពាណិជ្ជកម្ម គួរតែមានការត្រួតពិនិត្យឱ្យបានម៉ត់ចត់ទៅលើបញ្ហានានា ដែលកើតមាននៅក្នុងការធ្វើអាជីវកម្ម ដូចជាការដឹកទំនិញរបស់ក្រុមហ៊ុនដឹកទំនិញមួយចំនួនដែលបានអនុវត្តមិន

ស្របទៅតាមបទដ្ឋានច្បាប់ដូចជា ការប្រើប្រាស់ល្បឿនលើសកំណត់ ការផ្ទុកទំនិញលាយឡំនឹងការដឹកជញ្ជូនអ្នកដំណើរមានភាពណែនណាន់តាន់តាប់បាត់បរិយាកាសជាសុខភាព ព្រមទាំង ការត្រួតពិនិត្យលើសេវាមួយចំនួនដែលធានាថាការបំរើសេវានោះត្រូវតែមានសុវត្ថិភាព និង មានអនាម័យជាប់ជានិច្ច។

ម្យ៉ាងវិញទៀត ដោយសារតែប្រជាពលរដ្ឋកម្ពុជាមិនទាន់យល់ដឹងពីច្បាប់ នៅឡើយទេ អាស្រ័យហេតុនេះ ស្ថាប័នដែលពាក់ព័ន្ធ គួរតែធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដើម្បីឱ្យប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន មានការយល់ដឹងអំពីការអនុវត្តច្បាប់ ថែមទាំងអាចជួយកាត់បន្ថយនូវបញ្ហា និង វិវាទនានាទាក់ទងនឹងកិច្ចសន្យាដែលតែងតែកើតមានក្នុងជីវភាពប្រចាំថ្ងៃ ក៏ដូចជាសម្មភាពអាជីវកម្មផងដែរ។

យើងសង្ឃឹមថា ប្រតិបត្តិករ អាជីវករ ពាណិជ្ជករ រួមទាំងបុគ្គលដែលមានចំណងកាតព្វកិច្ចទាក់ទង នឹងសេវាកម្ម ពិតជាខិតខំស្វែងយល់ និង ដើរតាមបទដ្ឋានច្បាប់នានាព្រមទាំងអនុវត្តឱ្យកាន់តែប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ ប្រកបដោយការរស់នៅក្នុងភាពសុខសាន្ត សុវត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច។